**នៅចំពោះមុខការិយាល័យសហចៅក្រមស៊ើបអង្កេត**

**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

**សំណុំរឿងលេខ៖** ០០៣/០៧-០៩-២០០៩-អ.វ.ត.ក/ក.ស.ច.ស

**ភាគីដាក់ឯកសារ៖** មេធាវីការពារក្តីរបស់ មាស មុត

**ដាក់ជូន៖** សហចៅក្រមស៊ើបអង្កេត

**ភាសាដើម៖** អង់គ្លេស

**កាលបរិច្ឆេទឯកសារ៖** ថ្ងៃទី ១៩ ខែ ឧសភា ឆ្នាំ ២០១៦

**ឯកសារបកប្រែ**
**TRANSLATION/TRADUCTION**
ថ្ងៃ ខែ ឆ្នាំ (Date): 14-Jun-2016, 15:03
CMS/CFO: Sann Rada

**ចំណាត់ថ្នាក់ឯកសារ**

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ៖ សាធារណៈ

ចំណាត់ថ្នាក់ឯកសារដោយ ក.ស.ច.ស ឬ អង្គជំនុំជម្រះ៖ សាធារណៈ/Public

ចំណាត់ថ្នាក់ប្រភេទឯកសារ៖

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់បណ្តោះអាសន្ន៖

ឈ្មោះមន្ត្រីកត់ត្រា៖

ហត្ថលេខា៖

---

**សារណារបស់ មាស មុត ស្តីពីសំណួរថា តើតាមច្បាប់ទំនៀមទម្លាប់អន្តរជាតិនៅឆ្នាំ ១៩៧៥-១៩៧៩ ការវាយប្រហារដោយរដ្ឋ ឬ អង្គការទៅលើកងកម្លាំងប្រដាប់អាវុធរបស់ខ្លួន អាចជាការវាយប្រហារដែលសំដៅលើប្រជាជនស៊ីវិល តាមគោលបំណងនៃមាត្រា ៥ នៃ ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក. ឬយ៉ាងណា**

---

**ដាក់ដោយ÷**

**សហមេធាវី៖**

អាង ឧត្តម

Michael G. KARNAVAS

**ផ្ញើជូន÷**

**សហចៅក្រមស៊ើបអង្កេត៖**

ចៅក្រម យូ ប៊ុនឡេង

ចៅក្រម Michael BOHLANDER

**សហព្រះរាជអាជ្ញា៖**

លោកស្រី ជា លាង

លោក Nicholas KOUMJIAN

**ភាគីដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់**

ក្រុមមេធាវីការពារក្តី ០០៤

លោក មាស មុត តាមរយៈសហមេធាវីរបស់គាត់ ("មេធាវីការពារក្តី") តាមរយៈនេះ ដាក់សារណានេះ អនុលោមតាមសេចក្តីអំពាវនាវសុំឲ្យដាក់សារណា[1] របស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ។

## I. សេចក្តីសង្ខេបនៃបញ្ហា និង សារណា

*តើតាមច្បាប់ទំនៀមទម្លាប់អន្តរជាតិដែលអនុវត្តនៅឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩ ការវាយប្រហារដោយរដ្ឋ ឬ អង្គការទៅលើសមាជិកនៃកងកម្លាំងប្រដាប់អាវុធ* របស់ខ្លួន *អាចជាការវាយប្រហារដែលសំដៅលើប្រជាជនស៊ីវិល តាមគោលបំណងនៃមាត្រា ៥ នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក. ដែរឬទេ?*[2]

### *មូលដ្ឋាន និង តម្រុយរបស់ចៅក្រម*

ក. តាមមាត្រា ៥ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ "ត្រូវតែបានប្រព្រឹត្តឡើង *ក្នុងចំណោមនោះ* ជាផ្នែកមួយនៃការវាយប្រហារជាទូទៅ ឬ ជាប្រព័ន្ធ ដោយមានគោលដៅ *ចម្បង* សំដៅលើ '*ប្រជាជនស៊ីវិលណាមួយ*'"[3]។

ខ. "ស្របតាមយុត្តិសាស្ត្ររបស់សាលាក្តី *មិនអចិន្ត្រៃយ៍* ផ្សេងៗទៀត អង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់បំភ្លឺថា សមាជិកនៃអង្គការប្រដាប់អាវុធ បើទោះបីជា *គ្មានលទ្ធភាពប្រយុទ្ធ* (hors de combat) ក៏ដោយ ក៏មិនមែនជា "ជនស៊ីវិល" ដែរ តាមគោលបំណងនៃមាត្រា ៥..."[4]។

គ. "គោលការណ៍នេះត្រូវបានបញ្ជាក់ច្បាស់លាស់ទាក់ទងនឹងសមាជិកកងទ័ព ឬ ក្រុមប្រដាប់អាវុធ *ផ្សេងពី* សមាជិកកងទ័ព ឬ ក្រុមប្រដាប់អាវុធរបស់រដ្ឋ ឬ អង្គការដែលធ្វើការវាយប្រហារ ឬ និយាយម្យ៉ាងទៀត ជាសមាជិកកងទ័ព ឬ ក្រុមប្រដាប់អាវុធរបស់ *ខ្មាំង*"[5]។

---

[1] សេចក្តីអំពាវនាវសុំឲ្យដាក់សារណាពីភាគីនៅក្នុងសំណុំរឿង ០០៣ និង ០០៤ និង អ្នកដែលមិនមែនជាភាគី ចុះថ្ងៃទី ១៩ ខែមេសា ឆ្នាំ ២០១៦ ឯកសារ D191 ("សេចក្តីអំពាវនាវសុំឲ្យដាក់សារណា")។

[2] *ដូចខាងលើ* កថាខណ្ឌ ៣។

[3] *ដូចខាងលើ* កថាខណ្ឌ ១ (គូសបញ្ជាក់បន្ថែមទៅលើពាក្យថា "ចម្បង" សូមមើល កថាខណ្ឌ ២១)។

[4] *ដូចខាងលើ* កថាខណ្ឌ ២។

[5] *ដូចខាងលើ*។

ឃ. "អាចមានទឡ្ហីករណ៍មួយត្រូវបានលើកឡើងថា តាំងពីដើមដំបូងមកម្ល៉េះ ការពិភាក្សាកន្លងមកអំពីការបកស្រាយទស្សនទាននេះ អាចមើលរំលងផ្នែកគោលការណ៍សមហេតុផលដ៏សាមញ្ញដែលថា ភាពខុសគ្នារវាងយុទ្ធជន និង ជនស៊ីវិល អាចមាន តែក្នុងករណីដែលយើងនិយាយអំពីយុទ្ធជន និង ជនស៊ីវិលរបស់ *ខ្មាំង* ប៉ុណ្ណោះ"[6]។

ង. "វា ក) ទំនងជាប្រាកដណាស់ថា របបមួយដែលក្នុងគ្រាមានសន្តិភាព បានព្យាយាមបោសសម្អាតកងកម្លាំងប្រដាប់អាវុធរបស់ខ្លួន ឧទាហរណ៍ដូចជា ទាហានទាំងអស់ដែលមានជាតិពន្ធុ ឬ ជំនឿណាមួយនោះ អាចជាប់ពាក់ព័ន្ធនឹងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ពីព្រោះលក្ខណៈសម្បត្តិជាយុទ្ធជនរបស់ជនរងគ្រោះ គ្រាន់តែដោយសារពួកគាត់ជាទាហាននោះ នឹងមិនជាប់ពាក់ព័ន្ធទាល់តែសោះនៅក្នុងបរិបទនេះ និង (ខ) គ្មានមូលហេតុដែលត្រូវគិតផ្ទុយពីនេះទេ ប្រសិនបើយុទ្ធនាការបោសសម្អាតបែបនេះ បានកើតឡើងនៅក្នុងពេលមានជម្លោះប្រដាប់អាវុធ ឬ បើមិនដូច្នោះទេ ជាប់ទាក់ទងនឹងជម្លោះប្រដាប់អាវុធនោះ"[7]។

***ចម្លើយ***

ក. ការវាយប្រហារទៅលើទាហានរបស់រដ្ឋខ្លួនឯង *មិនមែន* ជាការវាយប្រហារទៅលើប្រជាជនស៊ីវិលនោះទេ បើទោះបីជាការវាយប្រហារបែបនេះ ជាការបោសសម្អាតកងកម្លាំងប្រដាប់អាវុធរបស់រដ្ឋដែលមានជាតិពន្ធុ ឬ ជំនឿណាមួយ ដែលត្រូវបានប្រព្រឹត្តក្នុងពេលមានសង្គ្រាម ឬ សន្តិភាពក៏ដោយ។

ខ. រដ្ឋមិនបោះបង់ចោលអធិបតេយ្យភាពរបស់ខ្លួន ដើម្បីរើសយកទាហានរបស់ខ្លួនឡើយនៅក្នុងពេលមានសន្តិភាព។ ទាហាន និង ជនស៊ីវិល ជាកម្មវត្ថុនៃបទដ្ឋាន និង ការការពារខុសគ្នាទោះជានៅក្នុងពេលមានសង្គ្រាម ឬ សន្តិភាព។

គ. អំពើរបស់របបមួយប្រឆាំងនឹងទាហានរបស់ខ្លួនក្នុងពេលមានសន្តិភាព អាចត្រូវបានដោះស្រាយតាមច្បាប់ជាតិ ឬ អាស្រ័យទៅតាមកាលៈទេសៈ អាចត្រូវបានកាត់ទោសក្នុងនាមជាឧក្រិដ្ឋកម្មប្រល័យពូជសាសន៍។

---

[6] *ដូចខាងលើ* កថាខណ្ឌ ៥។

[7] *ដូចខាងលើ*។

ឃ. ក្នុងពេលមានជម្លោះប្រដាប់អាវុធ ប្រសិនបើបុគ្គលមិនមែនជាជនស៊ីវិល (ដូចជាទាហានសកម្ម ទាហាន *គ្មានលទ្ធភាពប្រយុទ្ធ* ឬ ទាហានជាប់ឃុំ) ជាគោលដៅនៃការវាយប្រហារដោយរដ្ឋរបស់ខ្លួន ការវាយប្រហារបែបនេះអាចជាការរំលោភបំពានលើច្បាប់មនុស្សធម៌អន្តរជាតិ ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ឬ បទល្មើសជាតិ អាស្រ័យទៅតាមកាលៈទេសៈ។ ការវាយប្រហារបែបនេះមិនអាចជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិឡើយ។

## II. សារណា

**ក. សំណួរទី ១៖ តើមានផ្នែកគោលនយោបាយណាមួយ ដែលត្រូវបានមើលរំលងដែរឬទេ ទាក់ទងនឹងថាតើភាពខុសគ្នារវាងទាហាន និង ជនស៊ីវិល អាចមាន តែក្នុងករណីដែលនិយាយអំពីទាហាន និង ជនស៊ីវិលរបស់ខ្មាំងឬយ៉ាងណានោះ?**

**ចម្លើយ៖ ទេ។ ច្បាប់ទំនៀមទម្លាប់អន្តរជាតិ តែងតែញែកដាច់ពីគ្នារវាងទាហាន និង ជនស៊ីវិលនៅក្នុងបរិបទនេះ ដែលតម្រូវឱ្យឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិត្រូវតែសំដៅលើប្រជាជន *ស៊ីវិល*។ គ្មានទម្លាប់អនុវត្តន៍របស់រដ្ឋ ឬ *ទស្សនៈច្បាប់* (opinio juris) ចង្អុលបង្ហាញថា ភាពខុសគ្នារវាងទាហាន និង ជនស៊ីវិល គឺទាក់ទងតែនឹងប្រជាជនរបស់ខ្មាំងឡើយ។ យុត្តិសាស្ត្របង្ហាញថា ភាពខុសគ្នានេះ គឺជាប់ទាក់ទង សូម្បីតែនៅក្នុងពេលមានសន្តិភាព និង នៅពេលវាយតម្លៃលើការវាយប្រហាររបស់រដ្ឋទៅលើទាហានរបស់ខ្លួន។**

១. ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ “មានដើមកំណើតពីការពន្លាតឧក្រិដ្ឋកម្មសង្គ្រាម”[8]។ ច្បាប់សង្គ្រាមត្រូវបានចងក្រងលើកដំបូងជាអន្តរជាតិនៅក្នុងអនុសញ្ញាទីក្រុងឡាអេ នៅក្នុងឆ្នាំ ១៨៩៩ និង ឆ្នាំ ១៩០៧[9] និង អនុសញ្ញាទីក្រុងហ្សឺណែវ ឆ្នាំ ១៩៤៩[10] ដើម្បីគ្រប់គ្រងលើទង្វើរបស់រដ្ឋ និង

---

[8] M. CHERIF BASSIOUNI ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៅក្នុងច្បាប់ព្រហ្មទណ្ឌអន្តរជាតិ ៤៨ (បោះពុម្ពលើកទីពីរ ឆ្នាំ ១៩៩៩)។

[9] ទស្សនទាននៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដែលមាននៅក្នុងបុព្វកថា (the Martens Clause) នៃអនុសញ្ញាទីក្រុងឡាអេ (II) ទាក់ទងនឹងវិធាន និង ទំនៀមទម្លាប់នៃសង្គ្រាមផ្លូវគោក (Laws and Customs of War on Land) (ឆ្នាំ ១៨៩៩) និង អនុសញ្ញាទីក្រុងឡាអេ (IV) ទាក់ទងនឹងវិធាន និង ទំនៀមទម្លាប់នៃសង្គ្រាមផ្លូវគោក (ឆ្នាំ ១៩០៧)។

[10] អនុសញ្ញា (ទី I) ស្តីពីការធ្វើឱ្យប្រសើរឡើងនូវស្ថានភាពនៃអ្នករបួស និង អ្នកជំងឺក្នុងកងកម្លាំងប្រដាប់អាវុធក្នុងសមរភូមិ ទីក្រុងហ្សឺណែវ ចុះថ្ងៃទី ១២ ខែសីហា ឆ្នាំ ១៩៤៩ (“អនុសញ្ញាទីក្រុងហ្សឺណែវទី I”)។ អនុសញ្ញា (ទី II) ស្តីពីការធ្វើឱ្យប្រសើរឡើងនូវស្ថានភាពនៃសមាជិករបួស ឈឺ និង លិចនាវាក្នុងកងកម្លាំងប្រដាប់អាវុធនៅសមុទ្រ ទីក្រុងហ្សឺណែវ ចុះថ្ងៃទី ១២

កងកម្លាំងប្រដាប់អាវុធរបស់រដ្ឋក្នុងពេលមានសង្គ្រាម[11]។ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ត្រូវបានកំណត់យ៉ាងច្បាស់ថាជាប្រភេទបទល្មើសដាច់ដោយឡែកពីឧក្រិដ្ឋកម្មសង្គ្រាម នៅក្រោយសង្គ្រាមលោកលើកទី ២ ហេតុដូច្នេះ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិបំពេញឱ្យភាពខ្វះចន្លោះនៃច្បាប់សង្គ្រាម និង ការពារជនស៊ីវិលពីរដ្ឋរបស់ខ្លួន[12]។

២. ការបំបែកឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ចេញពីឧក្រិដ្ឋកម្មសង្គ្រាម ត្រូវបានធ្វើឡើងតាមរយៈការទទួលស្គាល់គោលការណ៍នៃភាពខុសគ្នា[13] ដែលជាបទដ្ឋាននៃច្បាប់ទំនៀមទម្លាប់អន្តរជាតិដែលជាមូលដ្ឋានគ្រឹះនៃច្បាប់សង្គ្រាម[14]។ គោលការណ៍នេះចែងថា គ្រប់ពេលទាំងអស់ ភាគីជម្លោះត្រូវ

---

ខែសីហា ឆ្នាំ ១៩៤៩។ អនុសញ្ញា (ទី III) ទាក់ទងនឹងការប្រព្រឹត្តលើឈ្លើយសឹក ទីក្រុងហ្សឺណែវ ចុះថ្ងៃទី ១២ ខែសីហា ឆ្នាំ ១៩៤៩។ អនុសញ្ញា (ទី IV) ទាក់ទងនឹងការការពារជនស៊ីវិលក្នុងពេលមានសង្គ្រាម ទីក្រុងហ្សឺណែវ ចុះថ្ងៃទី ១២ ខែសីហា ឆ្នាំ ១៩៤៩ ("អនុសញ្ញាទីក្រុងហ្សឺណែវទី IV")។

[11] ច្បាប់ទំនៀមទម្លាប់មនុស្សធម៌អន្តរជាតិ ភាគ ១៖ វិធាន xxxi, xxxiv (បោះពុម្ពផ្សាយដោយ Jean-Marie Henckaerts & Louise Doswald-Beck សារព័ត៌មានសកលវិទ្យាល័យ Cambridge ឆ្នាំ ២00៥) ("Henckaerts ច្បាប់ទំនៀមទម្លាប់មនុស្សធម៌អន្តរជាតិ ភាគ ១")។

[12] ក្នុងកំឡុងពេលសង្គ្រាមលោកលើកទី ២ បណ្ដាប្រទេសមហាអំណាចសម្ព័ន្ធមិត្តបានដឹងថា បទល្មើសជាច្រើនត្រូវបានប្រព្រឹត្តដោយកងកម្លាំងយោធាសម្ព័ន្ធមិត្ត មិនមែនជាឧក្រិដ្ឋកម្មសង្គ្រាមនោះទេតាមន័យចង្អៀត ពីព្រោះជនរងគ្រោះ គឺជាជនជាតិតែមួយជាមួយនឹងកងកម្លាំងយោធាសម្ព័ន្ធមិត្តទាំងនេះ។ អាស្រ័យហេតុនេះ ទស្សនទាននៃច្បាប់សង្គ្រាម ត្រូវបានពង្រីកដើម្បីផ្ដល់យុត្តិធម៌ដល់ជនស៊ីវិលដែលត្រូវបានវាយប្រហារដោយរដ្ឋរបស់ខ្លួន ឬ មិនអាចត្រូវបានចាត់ទុកថាស្ថិតក្រោមការកាន់កាប់របស់ខ្មាំង។ ប្រវត្តិពេញលេញនៃគណៈកម្មការឧក្រិដ្ឋកម្មសង្គ្រាមនៃអង្គការសហប្រជាជាតិ និង ការវិវឌ្ឍន៍នៃច្បាប់សង្គ្រាម ត្រូវបានចងក្រងដោយគណៈកម្មការឧក្រិដ្ឋកម្មសង្គ្រាមនៃអង្គការសហប្រជាជាតិ (His Majesty's Stationary Office ទីក្រុងឡុងដ៍ ឆ្នាំ ១៩៤៨) ជំពូក ៨ ទំព័រ ១៧៤-១៧៥។

[13] គោលការណ៍នៃភាពខុសគ្នានេះ កាន់តែមានសារៈសំខាន់ខ្លាំង ដោយសារច្បាប់មនុស្សធម៌អន្តរជាតិវិវឌ្ឍស្របជាមួយនឹងច្បាប់សង្គ្រាម ដើម្បីធានាឱ្យមានការការពារអ្នករបួស អ្នកជំងឺ អ្នកជាប់ឃុំ និង ជនស៊ីវិលរបស់រដ្ឋខ្មាំងក្នុងពេលមានជម្លោះប្រដាប់អាវុធ។ *សូមមើល* Henckaerts ច្បាប់ទំនៀមទម្លាប់មនុស្សធម៌អន្តរជាតិ ភាគ ១ ត្រង់ទំព័រ ៣-៤ ។

[14] គោលការណ៍នេះត្រូវបានទទួលស្គាល់ជាលើកដំបូងនៅក្នុងសេចក្ដីប្រកាសលុបចោលការប្រើប្រាស់អាវុធជាតិផ្ទុះមួយចំនួនក្នុងពេលមានសង្គ្រាមឆ្នាំ ១៨៦៨ St. Petersburg ចុះថ្ងៃទី ២៩ ខែវិច្ឆិកា/ថ្ងៃទី ១១ ខែធ្នូ ឆ្នាំ ១៨៦៨ បុព្វកថា។ ក្រោយមកគោលការណ៍នេះ ត្រូវបានចងក្រងនៅក្នុងពិធីសារបន្ថែម I និង II នៃអនុសញ្ញាទីក្រុងហ្សឺណែវឆ្នាំ ១៩៤៩ និង សៀវភៅណែនាំកងទ័ពជាតិមួយចំនួន។ *សូមមើល* គណៈកម្មាធិការកាកបាទក្រហមអន្តរជាតិ (ICRC) ពិធីសារបន្ថែមទៅលើអនុសញ្ញាទីក្រុងហ្សឺណែវ ចុះថ្ងៃទី ១២ ខែសីហា ឆ្នាំ ១៩៤៩ ដែលទាក់ទងទៅនឹងការការពារជនរងគ្រោះនៃជម្លោះប្រដាប់អាវុធអន្តរជាតិ 1125 UNTS 3 ចុះថ្ងៃទី ៨ ខែមិថុនា ឆ្នាំ ១៩៧៧ ("API") មាត្រា ៤៨ មាត្រា ៥១(២) មាត្រា ៥២(២)។ គណៈកម្មាធិការកាកបាទក្រហមអន្តរជាតិ (ICRC) ពិធីសារបន្ថែមទៅលើអនុសញ្ញាទីក្រុងហ្សឺណែវ ចុះថ្ងៃទី ១២ ខែសីហា ឆ្នាំ ១៩៤៩ ដែលទាក់ទងនឹង

តែញែកឲ្យដាច់ពីគ្នារវាងជនស៊ីវិល និង យុទ្ធជន។ ការវាយប្រហារអាចសំដៅលើតែយុទ្ធជនប៉ុណ្ណោះ មិនដែលសំដៅទៅលើជនស៊ីវិលឡើយ[15]។ ភាពខុសគ្នារវាងជនស៊ីវិល និង យុទ្ធជន គឺជាមូលដ្ឋានគ្រឹះនៃច្បាប់សង្គ្រាម និង ច្បាប់ព្រហ្មទណ្ឌអន្តរជាតិ[16] ដែលបង្ហាញឲ្យឃើញតាមរយៈការអនុវត្តឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ តែចំពោះការវាយប្រហារទៅលើប្រជាជនស៊ីវិលប៉ុណ្ណោះ ហើយមិនមែនចំពោះទាហានឡើយ តាមច្បាប់ទំនៀមទម្លាប់អន្តរជាតិ។

៣. ច្បាប់ទំនៀមទម្លាប់អន្តរជាតិជាធរមានទទួលស្គាល់នូវភាពខុសគ្នារវាងទាហាន និង ជនស៊ីវិល ដោយមិនគិតថាតើទាហាន និង ជនស៊ីវិលនេះ ជាសមាជិកនៃប្រជាជនខ្មាំង ឬ ជាសមាជិករបស់ប្រជាជនរដ្ឋខ្លួនឯងឡើយ។ គ្មានទម្លាប់អនុវត្តន៍របស់រដ្ឋ ឬ *ទស្សនៈច្បាប់* (ចាំបាច់សម្រាប់បង្កើតបានជាច្បាប់ទំនៀមទម្លាប់អន្តរជាតិ) ដែលចង្អុលបង្ហាញថា គោលដៅនៃការវាយប្រហារអាចជាអ្វីផ្សេង ក្រៅពីប្រជាជនស៊ីវិលឡើយ[17]។ ទោះជាក្នុងពេលសង្គ្រាម ឬ សន្តិភាព ប្រសិនបើរដ្ឋមានបំណងការពារទាហានពីឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិមែននោះ រដ្ឋទាំងនោះប្រាកដជាបានធ្វើសេចក្តីព្រាងលិខិតុបករណ៍អន្តរជាតិពាក់ព័ន្ធ ដែលកំណត់និយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដើម្បីផ្ទុះបញ្ចាំងពីចេតនានេះហើយ។ រដ្ឋទាំងនោះមិនបានធ្វើដូច្នេះឡើយ[18]។

---

ការការពារជនរងគ្រោះនៃជម្លោះប្រដាប់អាវុធមិនមែនអន្តរជាតិ ចុះថ្ងៃទី ៨ ខែមិថុនា ឆ្នាំ ១៩៧៧ 1125 UNTS 609 (“APII”) មាត្រា ១៣(២)។ Henckaerts ច្បាប់ទំនៀមទម្លាប់មនុស្សធម៌អន្តរជាតិ ភាគ ១ ត្រង់ទំព័រ ៣-៦។

[15] Henckaerts ច្បាប់ទំនៀមទម្លាប់មនុស្សធម៌អន្តរជាតិ ភាគ ១ វិធាន ១។

[16] *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Martić* សំណុំរឿងលេខ IT-95-11-A សាលក្រម ចុះថ្ងៃទី ៨ ខែតុលា ឆ្នាំ ២០០៨ កថាខណ្ឌ ២៩៩។

[17] ទម្លាប់អនុវត្តរបស់រដ្ឋកើតមាននៅកន្លែងដែលមាន “ការប្រើប្រាស់ជាប្រចាំ និង ស៊ីសង្វាក់គ្នា [នៃវិធាន ឬ គោលការណ៍] ដែលអនុវត្តដោយរដ្ឋពាក់ព័ន្ធ”។ រឿងក្តីសុំសិទ្ធិជ្រកកោន (ប្រទេសកូឡុំប៊ី/ប្រទេសប៉េរូ) *សាលក្រម របាយការណ៍របស់តុលាការយុត្តិធម៌អន្តរជាតិ ឆ្នាំ ១៩៥០* ទំព័រ ២៧៦។ ទស្សនៈច្បាប់ កើតមាននៅពេលដែលអំពើពាក់ព័ន្ធក្លាយជាទម្លាប់អនុវត្ត និង បង្ហាញ ឬ ត្រូវបានធ្វើឡើងដើម្បីបង្ហាញ ពីជំនឿរបស់រដ្ឋដែលថា ទម្លាប់អនុវត្តនេះគឺជាកាតព្វកិច្ចតាមច្បាប់។ *រឿងក្តីឧបទ្វីបសមុទ្រខាងជើង (ប្រទេសអាល្លឺម៉ង់ តទល់នឹង ប្រទេសដាណឺម៉ាក ប្រទេសអាល្លឺម៉ង់ តទល់នឹង ប្រទេសហូឡង់) សាលក្រម របាយការណ៍តុលាការយុត្តិធម៌អន្តរជាតិ ឆ្នាំ ១៩៦៩* ទំព័រ ៤៤ កថាខណ្ឌ ៧៧ ។

[18] ផ្ទុយទៅវិញ ដូចដែលបានពិភាក្សា *ខាងក្រោម* រដ្ឋមានបំណងឲ្យបញ្ហាបែបនេះ ត្រូវបានដោះស្រាយតាមរយៈច្បាប់ជាតិ។

៤. ធម្មនុញ្ញតុលាការយោធាអន្តរជាតិ ("IMT") និង តុលាការយោធាអន្តរជាតិសម្រាប់តំបន់ចុងបូព៌ា ("IMTFE") តម្រូវឱ្យឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិត្រូវបានប្រព្រឹត្តចំពោះប្រជាជនស៊ីវិល[19]។ ច្បាប់លេខ ១០ របស់ក្រុមប្រឹក្សាគ្រប់គ្រង ("CCL10") ក៏តម្រូវឱ្យអំពើដែលជាមូលដ្ឋាននៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ត្រូវបានប្រព្រឹត្តចំពោះប្រជាជនស៊ីវិលផងដែរ[20]។ គោលការណ៍ទីក្រុងនូរ៉ែប៊ែក (Nuremberg) ដែលចងក្រងគោលការណ៍នៃច្បាប់អន្តរជាតិទទួលស្គាល់ដោយធម្មនុញ្ញ និង សាលក្រម IMT[21] ឱ្យនិយមន័យឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិថា ជាឧក្រិដ្ឋកម្មដែលប្រព្រឹត្ត

---

[19] មាត្រា ៦(គ) នៃធម្មនុញ្ញរបស់តុលាការយោធាអន្តរជាតិ ឧបសម្ព័ន្ធនៃកិច្ចព្រមព្រៀងសម្រាប់ការផ្តន្ទាទោស និង ការដាក់ទណ្ឌកម្មលើឧក្រិដ្ឋជនសង្គ្រាមសំខាន់ៗនៃសម្ព័ន្ធមិត្តអឺរ៉ុប (European Axis) (ដែលត្រូវបានអនុម័ត និង ចូលជាធរមាននៅថ្ងៃទី ៨ ខែសីហា ឆ្នាំ ១៩៤៥) ៨២ UNTS ២៧៩ (គូសបញ្ជាក់បន្ថែម)៖ "ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ៖ សំដៅលើមនុស្សឃាត ការសម្លាប់រង្គាល ការធ្វើឱ្យក្លាយទៅជាទាសករ ការនិរទេស និង អំពើអមនុស្សធម៌ផ្សេងទៀត**ដែលប្រព្រឹត្តចំពោះប្រជាជនស៊ីវិល** នៅមុនពេល ឬ ក្នុងពេលសង្គ្រាម ឬ ជាការធ្វើទុក្ខបុកម្នេញដោយសារមូលហេតុនយោបាយ ជាតិសាសន៍ ឬ សាសនា ក្នុងការប្រព្រឹត្ត ឬ ទាក់ទងនឹងឧក្រិដ្ឋកម្មណាមួយក្នុងដែនយុត្តាធិការរបស់តុលាការនេះ ទោះជារំលោភ ឬ មិនរំលោភលើច្បាប់ជាតិរបស់ប្រទេសដែលឧក្រិដ្ឋកម្មនោះបានប្រព្រឹត្តក៏ដោយ"។ ក្រោយមក អនុសញ្ញាស្តីពីភាពមិនអាចអនុវត្តបាននៃអាជ្ញាយុកាលលើឧក្រិដ្ឋកម្មសង្គ្រាម និង ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ឆ្នាំ ១៩៦៨ បានកំណត់និយមន័យឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដោយយោងតាមធម្មនុញ្ញតុលាការយោធាអន្តរជាតិ។ មាត្រា I(ខ) នៃអនុសញ្ញាស្តីពីភាពមិនអាចអនុវត្តបាននៃអាជ្ញាយុកាលលើឧក្រិដ្ឋកម្មសង្គ្រាម និង ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ (ដែលត្រូវបានអនុម័តនៅថ្ងៃទី ២៦ ខែវិច្ឆិកា ឆ្នាំ ១៩៦៨ សេចក្តីសម្រេចមហាសន្និបាតលេខ ២៣៩១ (XXIII) និង ចូលជាធរមាននៅថ្ងៃទី ១១ ខែវិច្ឆិកា ឆ្នាំ ១៩៧០) ៧៥៤ UNTS ៧៣៖ "ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិទោះជាត្រូវបានប្រព្រឹត្តក្នុងពេលមានសង្គ្រាម ឬ ក្នុងពេលមានសន្តិភាព ដូចដែលឱ្យនិយមន័យក្នុងធម្មនុញ្ញរបស់តុលាការយោធាអន្តរជាតិ ទីក្រុងនូរ៉ែប៊ែក (Nűrnberg) នៅថ្ងៃទី ៨ ខែសីហា ឆ្នាំ ១៩៤៥..."។ មាត្រា៥(គ) នៃធម្មនុញ្ញរបស់តុលាការយោធាអន្តរជាតិសម្រាប់តំបន់ចុងបូព៌ា បទបញ្ជាទូទៅលេខ ១ ទីបញ្ជាការនៃមេបញ្ជាការកំពូលរបស់កងទ័ពសម្ព័ន្ធមិត្ត (ថ្ងៃទី ១៩ ខែមករា ឆ្នាំ ១៩៤៦) ៤ Bevans ២០ (ដែលត្រូវបានធ្វើវិសោធនកម្មនៅថ្ងៃទី ២៦ ខែមេសា ឆ្នាំ ១៩៤៦ ៤ Bevans ២៧) (គូសបញ្ជាក់បន្ថែម)៖ "ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ៖ សំដៅលើមនុស្សឃាត ការសម្លាប់រង្គាល ការធ្វើឱ្យក្លាយទៅជាទាសករ ការនិរទេស និង អំពើអមនុស្សធម៌ផ្សេងទៀត**ដែលប្រព្រឹត្តចំពោះប្រជាជនស៊ីវិល...**"។

[20] ច្បាប់លេខ ១០ របស់ក្រុមប្រឹក្សាគ្រប់គ្រង ការដាក់ទណ្ឌកម្មលើបុគ្គលដែលជាប់ទោសឧក្រិដ្ឋកម្មសង្គ្រាម ឧក្រិដ្ឋកម្មប្រឆាំងសន្តិភាព និង មនុស្សជាតិ ចុះថ្ងៃទី ២០ ខែធ្នូ ឆ្នាំ ១៩៤៥ ៣ រដ្ឋកិច្ចរបស់ក្រុមប្រឹក្សាគ្រប់គ្រងសម្រាប់ប្រទេសអាល្លឺម៉ង់ ៥០-៥៥ (ឆ្នាំ ១៩៤៦) មាត្រា II(គ) (គូសបញ្ជាក់បន្ថែម)៖ "អំពើឃោរឃៅ និង បទល្មើស ដែលរួមបញ្ចូល ប៉ុន្តែមិនកំណត់ត្រឹម មនុស្សឃាត ការសម្លាប់រង្គាល ការធ្វើឱ្យក្លាយទៅជាទាសករ ការនិរទេស ការដាក់ពន្ធនាគារ ការធ្វើទារុណកម្ម ការរំលោភសេពសន្ថវៈ ឬ អំពើអមនុស្សធម៌ផ្សេងទៀត **ដែលប្រព្រឹត្តចំពោះប្រជាជនស៊ីវិល** ឬ ការធ្វើទុក្ខបុកម្នេញដោយសារមូលហេតុនយោបាយ ជាតិសាសន៍ ឬ សាសនា ទោះជារំលោភ ឬ មិនរំលោភលើច្បាប់ជាតិរបស់ប្រទេសដែលឧក្រិដ្ឋកម្មត្រូវបានប្រព្រឹត្តក៏ដោយ"។

[21] មហាសន្និបាតរបស់អង្គការសហប្រជាជាតិ សេចក្តីសម្រេចលេខ ១៧៧ (II) *ការបង្កើតគោលការណ៍ដែលទទួលស្គាល់ក្នុងធម្មនុញ្ញតុលាការនូរ៉ែប៊ែក និង ក្នុងសាលក្រមរបស់តុលាការ* ចុះថ្ងៃទី ២១ ខែវិច្ឆិកា ឆ្នាំ ១៩៤៧។

ចំពោះប្រជាជនស៊ីវិល[22]។ ដើម្បីធ្វើឱ្យច្បាប់អន្តរជាតិជឿនលឿន គណៈកម្មការច្បាប់អន្តរជាតិ ("ILC") ដែលបានបង្កើតគោលការណ៍ទីក្រុងនូរ៉េប៊ែក បានតាក់តែងសេចក្តីព្រាងក្រមស្តីពីបទល្មើសប្រឆាំងសន្តិភាព និង សន្តិសុខរបស់មនុស្សជាតិនៅឆ្នាំ ១៩៥១ ឆ្នាំ ១៩៥៤ ឆ្នាំ ១៩៩១ និង ឆ្នាំ ១៩៩៦ ប៉ុន្តែគ្មានក្រមណាមួយក្នុងចំណោមក្រមទាំងនេះ ត្រូវបានអនុម័តឡើយ[23]។

---

[22] គោលការណ៍នៃច្បាប់អន្តរជាតិដែលទទួលស្គាល់ក្នុងធម្មនុញ្ញរបស់តុលាការនូរ៉េប៊ែក និង ក្នុងសាលក្រមរបស់តុលាការនូរ៉េប៊ែក សៀវភៅប្រចាំឆ្នាំទី ២ របស់គណៈកម្មការច្បាប់អន្តរជាតិ (ឆ្នាំ ១៩៥០) ៣៧៤-៧៨ គោលការណ៍ ៦(គ) (គូសបញ្ជាក់បន្ថែម)៖ មនុស្សឃាត ការសម្លាប់រង្គាល ការធ្វើឱ្យក្លាយទៅជាទាសករ ការនិរទេស និង អំពើអមនុស្សធម៌ផ្សេងទៀត**ដែលប្រព្រឹត្តចំពោះប្រជាជនស៊ីវិល** ឬ ការធ្វើទុក្ខបុកម្នេញដោយសារមូលហេតុនយោបាយ ជាតិសាសន៍ ឬ សាសនា..."។ ទោះបីជាលិខិតុបករណ៍ដែលត្រូវបានអនុម័តក្រោយពេលបញ្ចប់សង្គ្រាមលោកលើកទី ២ អាចត្រូវបានបកស្រាយដោយបុគ្គលមួយចំនួនថា មានតែឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដែលស្ថិតក្នុង "ប្រភេទមនុស្សឃាត" ប៉ុណ្ណោះដែលត្រូវតែប្រព្រឹត្តចំពោះប្រជាជនស៊ីវិល ក្នុងខណៈដែលការធ្វើទុក្ខបុកម្នេញអាចត្រូវបានប្រព្រឹត្តចំពោះប្រជាជនស៊ីវិល ឬ មិនមែនស៊ីវិលក៏ដោយ ក៏ការបកស្រាយរបៀបនេះ គឺមិនសមហេតុផលឡើយ។ ការបកស្រាយនេះអាចមានឫសគល់ពីការញែកដាច់ពីគ្នាជាក់ស្តែងក្នុងធម្មនុញ្ញ IMT និង IMTFE ច្បាប់លេខ ១០ របស់ក្រុមប្រឹក្សាគ្រប់គ្រង និង គោលការណ៍ទីក្រុងនូរ៉េប៊ែក រវាងឧក្រិដ្ឋកម្ម "ប្រភេទមនុស្សឃាត" ដែលប្រព្រឹត្តចំពោះប្រជាជនស៊ីវិល និង ការធ្វើទុក្ខបុកម្នេញ។ *សូមមើល* មាត្រា ៦(គ) នៃធម្មនុញ្ញ IMT។ មាត្រា ៥(គ) នៃធម្មនុញ្ញ IMTFE។ មាត្រា II(គ) នៃច្បាប់លេខ ១០ របស់ក្រុមប្រឹក្សាគ្រប់គ្រង។ គោលការណ៍ ៦(គ) នៃគោលការណ៍ទីក្រុងនូរ៉េប៊ែក។ ប្រសិនបើឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិអនុវត្តតែចំពោះប្រជាជនស៊ីវិល នៅក្នុងករណីមនុស្សឃាត ការសម្លាប់រង្គាល ការធ្វើឱ្យក្លាយទៅជាទាសករ ការនិរទេស ឬ អំពើអមនុស្សធម៌ផ្សេងទៀតដែលរងការចោទប្រកាន់ថាបានកើតឡើង ប៉ុន្តែអនុវត្តចំពោះប្រជាជន*គ្រប់ប្រភេទ*ទាំងអស់ក្នុងករណីការធ្វើទុក្ខបុកម្នេញនោះ នឹងធ្វើឱ្យមនុស្សដែលទទួលបានការការពារពីឧក្រិដ្ឋកម្មធ្ងន់ធ្ងរ (ដូចជាមនុស្សឃាត និង ការសម្លាប់រង្គាល) មានចំនួនតិចជាងមនុស្សដែលទទួលបានការការពារពីឧក្រិដ្ឋកម្មកម្រិតស្រាលជាង (ការធ្វើទុក្ខបុកម្នេញ)។ លទ្ធផលបែបនេះមិនស្របទៅនឹងដើមកំណើតនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិឡើយ។ *សូមមើល* Egon Schwelb *ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ* ២៣ BRIT.Y.B.INT'L L. ១៧៨ ១៩០ (ឆ្នាំ ១៩៤៦)។ Schwelb គូសបញ្ជាក់ផងដែរថា ពិធីសារអាល្លឺម៉ង់ចុះថ្ងៃទី ៦ ខែតុលា ឆ្នាំ ១៩៤៥ ដែលបានកែប្រែសញ្ញា (;) ក្រោយពាក្យ "សង្គ្រាម" ក្នុងឯកសារជាភាសាអង់គ្លេស និង ភាសាបារាំងនៃមាត្រា ៦(គ) ឱ្យទៅជាសញ្ញាក្បៀស (,) ដើម្បីឱ្យស្របគ្នានឹងឯកសារជាភាសារុស្ស៊ី ធ្វើឱ្យមានការបែងចែករវាងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ "ប្រភេទមនុស្សឃាត" និង ការធ្វើទុក្ខបុកម្នេញ គឺគ្មាននិរន្តរភាព។ *ដូចខាងលើ*។

[23] មហាសន្និបាតរបស់ អ.ស.ប. សេចក្តីសម្រេចលេខ ១៧៧(II) *ការបង្កើតគោលការណ៍ដែលទទួលស្គាល់ក្នុងធម្មនុញ្ញតុលាការនូរ៉េប៊ែក និង ក្នុងសាលក្រមរបស់តុលាការនូរ៉េប៊ែក* ចុះថ្ងៃទី ២១ ខែវិច្ឆិកា ឆ្នាំ ១៩៤៧។ សេចក្តីព្រាងក្រមរបស់ ILC ឆ្នាំ ១៩៥១ និង ឆ្នាំ ១៩៥៤ កំណត់និយមន័យឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដោយតម្រូវឱ្យមានការវាយប្រហារសំដៅលើប្រជាជនស៊ីវិល។ សេចក្តីព្រាងក្រមឆ្នាំ ១៩៩១ មិនបានឱ្យនិយមន័យឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិច្បាស់លាស់ឡើយ។ សេចក្តីព្រាងក្រមឆ្នាំ ១៩៩៦ បានកំណត់និយមន័យឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដោយគ្មានលក្ខខណ្ឌតម្រូវថាជាការវាយប្រហារសំដៅលើប្រជាជនស៊ីវិលឡើយ។ *សូមមើល* មាត្រា ២(១០) នៃសេចក្តីព្រាងក្រមស្តីពីបទល្មើសប្រឆាំងសន្តិភាព និង សន្តិសុខរបស់មនុស្សជាតិ សៀវភៅ

៥. ស្របនឹងលិខិតុបករណ៍ដែលបានលើកឡើងខាងលើ លក្ខន្តិកៈក្រោយឆ្នាំ ១៩៧៩ របស់សាលាក្តីអន្តរជាតិ និង អន្តរជាតូបនីយកម្ម ក៏បានបញ្ជាក់ផងដែរថា ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិតម្រូវឲ្យមានការវាយប្រហារចំពោះប្រជាជនស៊ីវិល។ សាលាក្តីព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី ("ICTY")[24] សាលាក្តីព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរវ៉ាន់ដា ("ICTR")[25] តុលាការពិសេសសម្រាប់ប្រទេសសៀរ៉ាឡេអូន ("SCSL")[26] និង គណៈកម្មការពិសេសសម្រាប់

---

ប្រចាំឆ្នាំទី ២ របស់គណៈកម្មការច្បាប់អន្តរជាតិ (ឆ្នាំ ១៩៥១) ១៣៣-៣៧។ មាត្រា ២(១១) នៃសេចក្តីព្រាងក្រមស្តីពីបទល្មើសប្រឆាំងសន្តិភាព និង សន្តិសុខរបស់មនុស្សជាតិ សៀវភៅប្រចាំឆ្នាំទី ២ របស់គណៈកម្មការច្បាប់អន្តរជាតិ (ឆ្នាំ ១៩៥៤)។ សេចក្តីព្រាងក្រមស្តីពីបទល្មើសប្រឆាំងសន្តិភាព និង សន្តិសុខរបស់មនុស្សជាតិ សៀវភៅប្រចាំឆ្នាំទី ២ របស់គណៈកម្មការច្បាប់អន្តរជាតិ ១០១-០៧ (ឆ្នាំ ១៩៩១)។ មាត្រា ១៨ នៃសេចក្តីព្រាងក្រមឆ្នាំ ១៩៩៦ ស្តីពីឧក្រិដ្ឋកម្មប្រឆាំងសន្តិភាព និង សន្តិសុខរបស់មនុស្សជាតិ ៥១ UN GAOR Supp. (លេខ ១០) ត្រង់ ១៤ ឯកសារ អ.ស.ប. A/CN.4/L.៥៣២ កែតម្រូវ ១ កែតម្រូវ ៣ (ឆ្នាំ ១៩៩៦)។ សេចក្តីព្រាងក្រមទាំងនេះមិនមែនជាច្បាប់ទំនៀមទម្លាប់អន្តរជាតិឡើយ។ សេចក្តីព្រាងទាំងនេះគ្រាន់តែជាឧទាហរណ៍នៃកិច្ចខិតខំប្រឹងប្រែងរបស់ ILC ក្នុងការធ្វើឲ្យច្បាប់អន្តរជាតិមានភាពជឿនលឿន មិនមែនចងក្រងច្បាប់ឡើយ។ មាត្រា ១ មាត្រា ១៥ នៃលក្ខន្តិកៈរបស់គណៈកម្មការច្បាប់អន្តរជាតិ ដែលអនុម័តដោយមហាសន្និបាតក្នុងសេចក្តីសម្រេចលេខ ១៧៤ (II) នៅថ្ងៃទី ២១ ខែវិច្ឆិកា ឆ្នាំ ១៩៤៧ ធ្វើវិសោធនកម្មដោយសេចក្តីសម្រេចលេខ ៤៨៥ (V) នៅថ្ងៃទី ១២ ខែធ្នូ ឆ្នាំ ១៩៥០ លេខ ៩៨៤ (X) នៅថ្ងៃទី ៣ ខែធ្នូ ឆ្នាំ ១៩៥៥ លេខ ៩៨៥ (X) នៅថ្ងៃទី ៣ ខែធ្នូ ឆ្នាំ ១៩៥៥ និង លេខ ៣៦/៣៩ នៅថ្ងៃទី ១៨ ខែវិច្ឆិកា ឆ្នាំ ១៩៨១។

[24] មាត្រា ៥ នៃលក្ខន្តិកៈបច្ចុប្បន្នរបស់សាលាក្តីឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវី (ខែកញ្ញា ឆ្នាំ ២០០៩) (គូសបញ្ជាក់បន្ថែម)៖ "សាលាក្តីអន្តរជាតិត្រូវមានអំណាចផ្តន្ទាទោសបុគ្គលដែលទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មដូចតទៅនេះដែលបានប្រព្រឹត្តក្នុងជម្លោះប្រដាប់អាវុធ... **និង សំដៅលើប្រជាជនស៊ីវិល**៖ ....."។ អ្នកតាក់តែងសេចក្តីព្រាងលក្ខន្តិកៈនេះបានដាក់បញ្ចូលតែបញ្ញត្តិដែលជាច្បាប់ទំនៀមទម្លាប់អន្តរជាតិ "លើសពីមតិសង្ស័យ"។ របាយការណ៍របស់អគ្គលេខាធិការអនុលោមតាមកថាខណ្ឌ ២ នៃសេចក្តីសម្រេចលេខ ៨០៨ របស់ក្រុមប្រឹក្សាសន្តិសុខ (ឆ្នាំ ១៩៩៣) ឯកសារ អ.ស.ប. S/២៥៧០៤ ចុះថ្ងៃទី ៣ ខែឧសភា ឆ្នាំ ១៩៩៣ កថាខណ្ឌ ៣៤៖ "យោងតាមការយល់ឃើញរបស់អគ្គលេខាធិការ ការអនុវត្តគោលការណ៍គ្មានច្បាប់គឺគ្មានទោស (nullum crimen sine lege) តម្រូវឲ្យសាលាក្តីអន្តរជាតិអនុវត្តវិធាននៃច្បាប់មនុស្សធម៌អន្តរជាតិដែលជាផ្នែកលើសពីមតិសង្ស័យក្នុងច្បាប់ទំនៀមទម្លាប់ ដើម្បីបញ្ចៀសបញ្ហាដែលកើតចេញពីការអនុវត្តអនុសញ្ញាជាក់លាក់របស់រដ្ឋមួយចំនួន"។ *សូមមើលផងដែរ ដូចខាងលើ* កថាខណ្ឌ ២៩។

[25] មាត្រា ៣ នៃលក្ខន្តិកៈរបស់សាលាក្តីឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់រវ៉ាន់ដា (ថ្ងៃទី ៣១ ខែមករា ឆ្នាំ ២០១០) (គូសបញ្ជាក់បន្ថែម)៖ "សាលាក្តីអន្តរជាតិសម្រាប់រវ៉ាន់ដា ត្រូវមានអំណាចផ្តន្ទាទោសបុគ្គលដែលទទួលខុសត្រូវលើឧក្រិដ្ឋកម្មដូចតទៅនេះ ដែលបានប្រព្រឹត្តជាផ្នែកមួយនៃការវាយប្រហារជាទូទៅ ឬ ជាប្រព័ន្ធ**ទៅលើប្រជាជនស៊ីវិល**ដោយសារមូលហេតុជាតិ នយោបាយ ជាតិពន្ធុ ជាតិសាសន៍ ឬ សាសនា៖ ....."។

[26] មាត្រា ២ នៃលក្ខន្តិកៈរបស់តុលាការពិសេសសម្រាប់ប្រទេសសៀរ៉ាឡេអូន ដែលអនុម័តដោយសេចក្តីសម្រេចលេខ ១៣១៥ របស់ក្រុមប្រឹក្សាសន្តិសុខនៃ អ.ស.ប. (ថ្ងៃទី ១៤ ខែសីហា ឆ្នាំ ២០០០)។

ឧក្រិដ្ឋកម្មធ្ងន់ធ្ងរក្នុងប្រទេសទីម័រខាងកើត[27] ដែលសុទ្ធតែត្រូវបានបង្កើតឡើងនៅក្រោយពេល ឬក្នុងពេលនៃការប្រព្រឹត្តិឧក្រិដ្ឋកម្មដែលតុលាការទាំងនេះត្រូវបានបង្កើតឡើង ដើម្បីដោះស្រាយតម្រូវឱ្យអនុវត្តច្បាប់ទំនៀមទម្លាប់អន្តរជាតិដែលបានព្រមព្រៀង[28]។ តុលាការទាំងនេះមិនអាចបង្កើតច្បាប់ថ្មីដើម្បីអនុវត្ត *ជាប្រតិសកម្ម* (ex post facto) បានឡើយ។ លក្ខន្តិកៈទាំងនេះឆ្លុះបញ្ចាំងនូវការយល់ដឹងស៊ីសង្វាក់គ្នារបស់បណ្តារដ្ឋ (និង អង្គការសហប្រជាជាតិ) ស្តីពីច្បាប់ទំនៀមទម្លាប់អន្តរជាតិ ចាប់តាំងពីមានគោលការណ៍ទីក្រុងនូរ៉ំប៊ែក។

៦. តាមលក្ខន្តិកៈទីក្រុងរ៉ូមនៃតុលាការព្រហ្មទណ្ឌអន្តរជាតិ (“ICC”) ការវាយប្រហារដែលសំដៅលើប្រជាជនស៊ីវិល គឺជាធាតុផ្សំចាំបាច់នៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ[29]។ ដោយហេតុថាលក្ខន្តិកៈទីក្រុងរ៉ូមអាចត្រូវអនុវត្តតែនៅថ្ងៃខាងមុខនោះ ប្រសិនបើបណ្តារដ្ឋយល់ថា មានកង្វះការការពារដែលមិនអាចទទួលយកបាន និង ពិចារណាឃើញថា ច្បាប់ទំនៀមទម្លាប់អន្តរជាតិបានវិវឌ្ឍដល់កម្រិតដែលថា នៅក្រោមកាលៈទេសៈមួយចំនួន កងកម្លាំងប្រដាប់អាវុធផ្ទាល់របស់រដ្ឋអាចត្រូវបានចាត់ទុកជាប្រជាជនស៊ីវិលនោះ រដ្ឋទាំងនោះគួរតែបានដាក់បញ្ចូលភាសានេះក្នុងនិយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ។ បន្ទាប់ពីដំណើរការធ្វើសេចក្តីព្រាងច្បាប់អស់រយៈពេល ៣ ឆ្នាំ រដ្ឋភាគីទាំង ១៦០ បានជ្រើសរើសមិនកែប្រែនិយមន័យនេះ[30]។

៧. ស្រដៀងគ្នានេះដែរ សេចក្តីព្រាងអនុសញ្ញាស្តីពីឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដែលបច្ចុប្បន្ននេះស្នើដោយ ILC អាចដកចេញលក្ខខណ្ឌដែលតម្រូវឱ្យគោលដៅនៃការវាយប្រហារជាប្រជាជនស៊ីវិល

---

[27] មាត្រា ៥(១) នៃបទប្បញ្ញត្តិស្តីពីការបង្កើតគណៈកម្មការដែលមានយុត្តាធិការផ្តាច់មុខលើបទល្មើសឧក្រិដ្ឋធ្ងន់ធ្ងរ ដែលអនុម័តដោយរដ្ឋបាលបណ្តោះអាសន្នរបស់ អ.ស.ប. ប្រចាំប្រទេសទីម័រខាងកើត ឯកសារ អ.ស.ប. UNTAET/REG/២០០០/១៥ (ថ្ងៃទី ៦ ខែមិថុនា ឆ្នាំ ២០០០)។

[28] *សូមមើល ឧ.* របាយការណ៍របស់អគ្គលេខាធិការ អនុលោមតាមកថាខណ្ឌ ២ នៃសេចក្តីសម្រេចលេខ ៨០៨ របស់ក្រុមប្រឹក្សាសន្តិសុខ (ឆ្នាំ ១៩៩៣) ឯកសារ អ.ស.ប. S/២៥៧០៤ ចុះថ្ងៃទី ៣ ខែឧសភា ឆ្នាំ ១៩៩៣ កថាខណ្ឌ ៣៤។

[29] មាត្រា ៧ នៃលក្ខន្តិកៈទីក្រុងរ៉ូមរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ ដែលបានសម្រេចនៅទីក្រុងរ៉ូមនៅថ្ងៃទី ១៧ ខែកក្កដា ឆ្នាំ ១៩៩៨ ចូលជាធរមាននៅថ្ងៃទី ១ ខែកក្កដា ឆ្នាំ ២០០២ ២១៨៧ UNTS ៣៨៥៤៤។

[30] ដោយហេតុថា រដ្ឋភាគីទាំង ១៦០ បានចូលរួមក្នុងដំណើរការព្រាងលក្ខន្តិកៈទីក្រុងរ៉ូមក្នុងរយៈពេល ៣ ឆ្នាំនោះ ការណ៍នេះត្រូវបានចាត់ទុកថា ជាការបង្ហាញពីសញ្ញារឹងមាំនៃ *ទស្សនៈច្បាប់* របស់សហគមន៍អន្តរជាតិ ទាក់ទងនឹងច្បាប់ទំនៀមទម្លាប់អន្តរជាតិស្តីពីឧក្រិដ្ឋកម្ម។ DOMINIC MCGOLDRICK និង អ្នកផ្សេងទៀត តុលាការព្រហ្មទណ្ឌអន្តរជាតិអចិន្ត្រៃយ៍៖ បញ្ហាផ្លូវច្បាប់ និង គោលនយោបាយ ៣៤០ (Hart Publishing បោះពុម្ពលើកទី ១ ឆ្នាំ ២០០៤)។

ប្រសិនបើអ្នកធ្វើសេចក្តីព្រាង បានយល់ឃើញថា ត្រូវមានការការពារទាហានផ្ទាល់របស់រដ្ឋ តាមច្បាប់ព្រហ្មទណ្ឌអន្តរជាតិនោះ។ ប៉ុន្តែ សេចក្តីព្រាងឆ្នាំ ២០១៥ រក្សាទុកបន្តនូវលក្ខខណ្ឌស៊ីសង្វាក់គ្នាដែលថា ការវាយប្រហារត្រូវតែសំដៅលើប្រជាជនស៊ីវិល[31]។

***និយមន័យប្រជាជនស៊ីវិល***

៨. តាំងពីនូវរំប៉ែករហូតមកដល់បច្ចុប្បន្ននេះ គ្មានលក្ខន្តិកៈណាមួយឲ្យនិយមន័យពាក្យ "ប្រជាជនស៊ីវិល" ឡើយ។ ទោះជាយ៉ាងនេះក្តី និយមន័យនៃពាក្យ "ប្រជាជនស៊ីវិល" មានចែងក្នុងលិខិតុបករណ៍អន្តរជាតិចំនួន ២ ដែលមានកាលបរិច្ឆេទមុនឆ្នាំ ១៩៧៥ គឺសេចក្តីព្រាងអនុសញ្ញាសម្រាប់ការការពារប្រជាជនស៊ីវិលប្រឆាំងនឹងចលករសង្គ្រាមថ្មីឆ្នាំ ១៩៣៨[32] និង សេចក្តីព្រាងវិធានឆ្នាំ ១៩៥៦ របស់គណៈកម្មាធិការកាកបាទក្រហម និង អឌ្ឍច័ន្ទក្រហមអន្តរជាតិ ("ICRC") សម្រាប់កម្រិតគ្រោះថ្នាក់ដែលជួបប្រទះដោយប្រជាជនស៊ីវិលក្នុងពេលសង្គ្រាម[33]។ លិខិតុបករណ៍ទាំងពីរនេះសុទ្ធតែឲ្យនិយមន័យពាក្យ "ប្រជាជនស៊ីវិល" ថាជាជនទាំងឡាយណាដែលមិនមែនជាសមាជិកកងកម្លាំងប្រដាប់អាវុធ ឬ យុទ្ធជន។ និយមន័យនៃពាក្យ "ប្រជាជនស៊ីវិល" ទាំងនេះ

---

[31] មហាសន្និបាត អ.ស.ប. តំណាងរបស់គណៈកម្មការច្បាប់អន្តរជាតិ (ILC) *របាយការណ៍ទីមួយស្តីពីឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ* កថាខណ្ឌ ១៧៧ ឯកសារ អ.ស.ប. A/CN.៤/៦៨០ (ថ្ងៃទី ១៧ ខែកុម្ភៈ ឆ្នាំ ២០១៥)។

[32] សមាគមច្បាប់អន្តរជាតិ (ILA) សេចក្តីព្រាងអនុសញ្ញាសម្រាប់ការការពារប្រជាជនស៊ីវិលប្រឆាំងនឹងចលករសង្គ្រាមថ្មី ទីក្រុងអាំស្ទែដាំ ដែលត្រូវបានអនុម័តនៅក្នុងសន្និសីទលើកទី ៤០ របស់ ILA នៅអំឡុងថ្ងៃទី ២៩ ខែសីហា ដល់ថ្ងៃទី ២ ខែកញ្ញា ឆ្នាំ ១៩៣៨។ មាត្រា ១ ចែងថា៖ "ពាក្យ 'ប្រជាជនស៊ីវិល' ក្នុងអត្ថន័យនៃអនុសញ្ញានេះ ត្រូវរួមបញ្ចូលទាំងទាហានទាំងអស់ដែលមិនបានចូលបម្រើទ័ពនៅក្នុងផ្នែកណាមួយនៃសេវាយុទ្ធជន ឬ នៅពេលនោះមិនត្រូវបានឲ្យបម្រើការងារ ឬ កាន់ដំណែងក្នុងស្ថាប័នយុទ្ធការីដូចមានចែងក្នុងមាត្រា ២"។

[33] គណៈកម្មាធិការកាកបាទក្រហម និង អឌ្ឍច័ន្ទក្រហមអន្តរជាតិ (ICRC) សេចក្តីព្រាងវិធានសម្រាប់ការកម្រិតគ្រោះថ្នាក់ដែលជួបប្រទះដោយប្រជាជនស៊ីវិលក្នុងពេលសង្គ្រាម ទីក្រុងហ្សឺណែវ ខែកញ្ញា ឆ្នាំ ១៩៥៦។ មាត្រា ៤ ចែងថា៖ "ប្រជាជនស៊ីវិល គឺមនុស្សគ្រប់រូបដែលមិនស្ថិតក្នុងប្រភេទណាមួយ ដូចតទៅនេះ (ក) សមាជិកកងកម្លាំងប្រដាប់អាវុធ ឬ អង្គការជំនួយ ឬ បំពេញបន្ថែមរបស់កងកម្លាំងប្រដាប់អាវុធ (ខ) បុគ្គលដែលមិនស្ថិតក្នុងកងកម្លាំងដែលមានរៀបរាប់ក្នុងចំណុចខាងលើ ប៉ុន្តែចូលរួមក្នុងការប្រយុទ្ធ"។

ស្របគ្នានឹងអត្ថន័យធម្មតានៃពាក្យ "ជនស៊ីវិល"៖ "ជនដែលមិនស្ថិតក្នុងកងកម្លាំងប្រដាប់អាវុធ ឬ កងកម្លាំងប៉ូលីស"[34]។

៩. យុត្តិសាស្ត្ររបស់សាលាក្តី *មិនអចិន្ត្រៃយ៍* បកស្រាយពាក្យ "ប្រជាជនស៊ីវិល" និង បកស្រាយថាតើទាហានអាចត្រូវបានចាត់ទុកជាជនស៊ីវិល ឬយ៉ាងណា។ លក្ខខណ្ឌតម្រូវដែលថា ការវាយប្រហារត្រូវតែសំដៅលើប្រជាជនស៊ីវិល នៅតែរក្សាដដែល។ គ្មានការបង្ហាញថា អត្ថន័យនៃពាក្យ "ប្រជាជនស៊ីវិល" ត្រូវបានបកស្រាយផ្សេងពីនេះឡើយក្រោយឆ្នាំ ១៩៧៩។

១០. សាលាក្តីទាំងនេះសុទ្ធតែបានកំណត់ដូចៗគ្នាថា ប្រជាជនគោលដៅត្រូវតែមានលក្ខណៈជាជនស៊ីវិលយ៉ាងលើសលុប ទោះបីជាមានវត្តមានរបស់ជនមួយចំនួនដែលមិនមែនជាជនស៊ីវិលក្នុងចំណោមនោះក៏ដោយ ក៏ *មិន* ផ្លាស់ប្តូរលក្ខណៈនៃប្រជាជននេះដែរ[35]។ សាលាក្តី ICTY បានពឹងផ្អែកលើពិធីសារបន្ថែម I ដើម្បីកំណត់និយមន័យនៃពាក្យ "ជនស៊ីវិល"[36]។ ដូចដែលអង្គជំនុំជម្រះសាលាដំបូង អ.វ.ត.ក. បានគូសបញ្ជាក់ និយមន័យនេះស្របគ្នានឹងអត្ថន័យធម្មតានៃពាក្យ "ជនស៊ីវិល"[37]។

---

[34] *សូមមើល* ច្បាប់ទំនៀមទម្លាប់មនុស្សធម៌អន្តរជាតិ ភាគ ២៖ ទម្លាប់អនុវត្ត កថាខណ្ឌ ៧១២-៤៨ (បោះពុម្ពផ្សាយដោយ Jean-Marie Henckaerts & Louise Doswald-Beck សារព័ត៌មានសកលវិទ្យាល័យ Cambridge ឆ្នាំ ២០០៥) ដែលកំណត់និយមន័យនៃពាក្យជនស៊ីវិលក្នុងសៀវភៅណែនាំកងទ័ពរបស់បណ្តារដ្ឋនានា។ និយមន័យធម្មតានៃពាក្យ "ជនស៊ីវិល" នៅក្នុងសៀវភៅណែនាំទាំងនេះស្របគ្នានឹងនិយមន័យក្នុងវចនានុក្រម CONCISE OXFORD ENGLISH DICTIONARY ២៦១ (បោះពុម្ពលើកទី ១០ ឆ្នាំ ២០០២)។

[35] *សូមមើល ឧ. រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Tadić* សំណុំរឿងលេខ IT-94-1-T សាលក្រម ចុះថ្ងៃទី ៧ ខែឧសភា ឆ្នាំ ១៩៩៧ កថាខណ្ឌ ៦៣៨។ *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Kordić & Čerkez* សំណុំរឿងលេខ IT-95-14/2-A សាលក្រម ចុះថ្ងៃទី ១៧ ខែធ្នូ ឆ្នាំ ២០០៤ កថាខណ្ឌ ៩១។ *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Galić* សំណុំរឿងលេខ IT-98-29-A សាលក្រម ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ ២០០៦ កថាខណ្ឌ ១៣៦។ *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Miolšević* សំណុំរឿងលេខ IT-98-29/1-A សាលក្រម ចុះថ្ងៃទី ១២ ខែវិច្ឆិកា ឆ្នាំ ២០០៩ កថាខណ្ឌ ៥០។ *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Akayesu* សំណុំរឿងលេខ ICTR-96-4-T សាលក្រម ចុះថ្ងៃទី ២ ខែកញ្ញា ឆ្នាំ ១៩៩៨ កថាខណ្ឌ ៥៨២។ *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Fofana & Kondewa* សំណុំរឿងលេខ SCSL-04-14-A សាលក្រម ចុះថ្ងៃទី ២៨ ខែឧសភា ឆ្នាំ ២០០៨ កថាខណ្ឌ ២៥៨។

[36] *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Blaškić* សំណុំរឿងលេខ IT-95-14-A សាលក្រម ចុះថ្ងៃទី ២៩ ខែកក្កដា ឆ្នាំ ២០០៤ កថាខណ្ឌ ១១០-១៣។

[37] *រឿងក្តី នួន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ សាលក្រមរឿងក្តី ០០២/១ ចុះថ្ងៃទី ៧ ខែសីហា ឆ្នាំ ២០១៤ ឯកសារ E313 កថាខណ្ឌ ១៨៥ (ឯកសារយោងខាងក្នុងត្រូវបានលុបចោល)៖ "និយមន័យ

១១. សូម្បីតែនៅពេលពិចារណាលើឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដែលបានកើតឡើងក្នុងពេលមានសន្តិភាព អង្គជំនុំជម្រះសាលាដំបូងសាលាក្តី ICTR ក្នុងរឿងក្តី *Kayishema* បានតម្រូវឱ្យប្រជាជនត្រូវតែជាជនស៊ីវិល និង បានសម្រេចថា ប្រជាជនស៊ីវិល "រួមមានបុគ្គលគ្រប់រូប *លើកលែងតែ* ជនដែលមានភារកិច្ចរក្សាសណ្តាប់ធ្នាប់សាធារណៈ និង មានមធ្យោបាយស្របច្បាប់ក្នុងការប្រើប្រាស់កម្លាំង"[38]។ ការបកស្រាយពាក្យ "ជនស៊ីវិល" នេះ ត្រូវបានដកស្រង់ដោយមានការយល់ស្របនៅពេលថ្មីៗនេះ ដោយអ្នករាយការណ៍ពិសេសលើប្រធានបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ[39]។ រឿងក្តី *Kayishema* បង្ហាញថា សូម្បីតែនិយមន័យទូលំទូលាយនៃពាក្យ "ជនស៊ីវិល" ក៏ដកទាហានចេញដែរ ហើយភាពខុសគ្នារវាងជនស៊ីវិល និង ទាហាននៅតែរក្សាខ្លឹមសារសំខាន់របស់វាដដែល បើទោះបីជាស្ថិតនៅក្រៅបរិបទជម្លោះប្រដាប់អាវុធក៏ដោយ។

១២. អង្គជំនុំជម្រះសាលាឧទ្ធរណ៍សាលាក្តី ICTY ក្នុងរឿងក្តី *Martić* បានធ្វើការពិចារណាថាតើទាហាន *ដែលគ្មានលទ្ធភាពប្រយុទ្ធ* អាចត្រូវបានចាត់ទុកជាជនស៊ីវិលដើម្បីកំណត់លក្ខណៈជាជនស៊ីវិលនៃប្រជាជនឬយ៉ាងណា និង បានសម្រេចថា ពួកគេមិនអាចជាជនស៊ីវិលនោះទេ ប៉ុន្តែពួកគេអាចជាជនរងគ្រោះនៃឧក្រិដ្ឋកម្មដែលជាមូលដ្ឋាន[40]។ ក្នុងរឿងក្តី *Martić* ជន *ដែលគ្មាន*

---

ធម្មតានៃពាក្យថា "civilian" (ជាភាសាអង់គ្លេស) និង *"civil"* (ជាភាសាបារាំង) សំដៅទៅលើបុគ្គលទាំងឡាយណាដែលមិនមែនជាសមាជិកនៃកងកម្លាំងប្រដាប់អាវុធ។ នៅក្នុងរយៈពេលដែលជាប់ពាក់ព័ន្ធនឹងបទចោទប្រកាន់ដែលជាបញ្ហានៅទីនេះ ប្រជាជនស៊ីវិលរាប់បញ្ចូលគ្រប់បុគ្គលទាំងអស់ដែលមិនមែនជាសមាជិកនៃកងកម្លាំងប្រដាប់អាវុធ ឬ បើមិនដូច្នោះទេ ជនដែលត្រូវបានទទួលស្គាល់ថាជាយុទ្ធជន.... ខណៈដែលនៅទីនេះអង្គជំនុំជម្រះមិនបានពឹងផ្អែកលើនិយមន័យនៃពាក្យ "ជនស៊ីវិល" ដូចមានចែងក្នុងមាត្រា ៥០ នៃពិធីសារបន្ថែម I នៃអនុសញ្ញាទីក្រុងហ្សឺណែវ ឆ្នាំ ១៩៤៩ ដែលទទួលយកដោយសាលាក្តីមិនអចិន្ត្រៃយ៍ ថាឆ្លុះបញ្ចាំងច្បាប់ទំនៀមទម្លាប់អន្តរជាតិ សម្រាប់គោលបំណងនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិក្រោយឆ្នាំ ១៩៧៧ អង្គជំនុំជម្រះកត់សម្គាល់ថា និយមន័យនេះស្របជាមួយនឹងអត្ថន័យធម្មតានៃពាក្យនេះ"។

[38] *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង* *Kayishema & Ruzindanan* សំណុំរឿងលេខ ICTR-95-1-T សាលក្រម ចុះថ្ងៃទី ២១ ខែឧសភា ឆ្នាំ ១៩៩៩ កថាខណ្ឌ ១២៧ (គូសបញ្ជាក់ក្នុងឯកសារដើម)។

[39] មហាសន្និបាត អ.ស.ប. តំណាងរបស់គណៈកម្មការច្បាប់អន្តរជាតិ (ILC) *របាយការណ៍ទីមួយស្តីពីឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ* ឯកសារ អ.ស.ប. A/CN.៤/៦៨០ (ថ្ងៃទី ១៧ ខែកុម្ភៈឆ្នាំ ២០១៥) លេខ ២៧២។

[40] *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង* *Martić* សំណុំរឿងលេខ IT-95-11-A សាលក្រម ចុះថ្ងៃទី ៨ ខែតុលា ឆ្នាំ ២០០៨ កថាខណ្ឌ ២៩១-៣១៤ ជាពិសេស កថាខណ្ឌ ៣០២ កថាខណ្ឌ ៣១១។ អង្គជំនុំជម្រះសាលាដំបូង SCSL ក្នុងរឿងក្តី *Taylor* ក៏បានសម្រេចផងដែរថា ទាហាន *ដែលគ្មានលទ្ធភាពប្រយុទ្ធ* មិនអាចត្រូវបានចាត់ទុកជាជនស៊ីវិលឡើយ ទោះបីជាព្រះរាជអាជ្ញា និងចុងចម្លើយ បានព្រមព្រៀងគ្នាលើនិយមន័យទូលំទូលាយនៃជនស៊ីវិលដែលរួមបញ្ចូលជន *ដែលគ្មានលទ្ធភាពប្រយុទ្ធ* ក៏ដោយ។

*លទ្ធភាពប្រយុទ្ធ* មិនមែនជាផ្នែកនៃ "ប្រជាជនស៊ីវិល" ឡើយ។ រឿងក្តី *Martić* បង្ហាញពីសារៈសំខាន់នៃភាពខុសគ្នារវាងទាហាន និង ជនស៊ីវិល សូម្បីតែនៅពេលដែលទាហានលែងចូលរួមយ៉ាងសកម្មក្នុងការប្រទូស្តសារ៉ាយ និង លែងជាការគំរាមកំហែងដល់រដ្ឋ[41]។

១៣. រឿងក្តី *Prlić និង អ្នកផ្សេងទៀត* ថ្មីៗនេះរបស់សាលាក្តី ICTY បង្ហាញដោយតណ្ហីភាពថា ខណៈដែលអង្គជំនុំជម្រះសាលាដំបូង ICTY ទទួលស្គាល់ថា ទាហានរបស់រដ្ឋអាចតម្រូវឲ្យមានការការពារ ពួកគេនៅតែមិនត្រូវបានចាត់ទុកជាផ្នែកមួយនៃប្រជាជនស៊ីវិលសម្រាប់គោលបំណងនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ។ អង្គជំនុំជម្រះសាលាដំបូងបានធ្វើការពិចារណាទៅលើការអនុវត្តការរំលោភបំពានធ្ងន់ធ្ងរនៃអនុសញ្ញាទីក្រុងហ្សឺណែវ និង ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដែលកើតចេញពីការប្រព្រឹត្តិទៅលើសមាជិកមូស្លីមនៃក្រុមប្រឹក្សាការពារក្រូអាស៊ី ("HVO") (ស្ថាប័នយោធា

---

*រឿងក្តី រដ្ឋអាជ្ញា តទល់នឹង* *Taylor* សំណុំរឿងលេខ SCSL-03-01-T សាលក្រម ចុះថ្ងៃទី ១៨ ខែឧសភា ឆ្នាំ ២០១២ កថាខណ្ឌ ៥០៨-១០។ ពីដើមឡើយ យុត្តិសាស្ត្រឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិមិនស្របគ្នាទាក់ទងនឹងចំណុចថា តើទាហានអាចជាជនរងគ្រោះនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ឬយ៉ាងណា។ ខណៈដែលនៅក្នុងរឿងក្តីខ្លះ តុលាការបានចាត់ទុកថា *ជនរងគ្រោះ* នៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ អាចជាទាហាន (*សូមមើល* សេចក្តីសង្ខេបនៃរឿងក្តីបែបនេះមួយចំនួនក្នុង Hansdeep Singgh *ការរិះគន់លើសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ICTY ក្នុងរឿងក្តី Mrkšić* (Critique of the Mrkšić Trial Chamber (ICTY) ៨ LAW & PRAC. INT'L CTS. & TRIB. ២៤៧ ២៥៧-៥៩ (ឆ្នាំ ២០០៩)។ *សូមមើលផងដែរ* តុលាការកំពូលសភាព្រហ្មទណ្ឌ [តុលាការកំពូលបារាំង សភាព្រហ្មទណ្ឌ] ចុះថ្ងៃទី ២០ ខែធ្នូ ឆ្នាំ ១៩៨៥ (រឿងក្តី Barbie) បណ្តឹងសាទុក្ខលេខ ៨៥-៩៥១៦៦) តុលាការផ្សេងទៀត បានបដិសេធគោលជំហរដែលថា ទាហានអាចជាជនរងគ្រោះ ដោយសារពួកគេមិនមែនជាផ្នែកនៃប្រជាជនស៊ីវិល (*សូមមើល ឧ. ក្នុងរឿងក្តី Pilz* តុលាការកំពូលពិសេស ចុះថ្ងៃទី ៥ ខែកក្កដា ឆ្នាំ ១៩៥០។ *សូមមើលផងដែរ* Emily Haslam *រឿងក្តី Neddermeier ក្នុង* THE OXFORD COMPANION TO INTERNATIONAL CRIMINAL JUSTICE 840 (បោះពុម្ពផ្សាយដោយ Antonio Cassese សារព័ត៌មានសកលវិទ្យាល័យ Oxford ឆ្នាំ ២០០៩) *ដែលសង្ខេបរឿងក្តី* Neddermeier *តទល់នឹង ប្រធានអង្គអយ្យការ* សាលាឧទ្ធរណ៍ចក្រភពអង់គ្លេសប្រចាំប្រទេសអាល្លឺម៉ង់ ចុះថ្ងៃទី ៣០ ខែកញ្ញា ឆ្នាំ ១៩៤៨ ក្នុងតុលាការគណៈកម្មការគ្រប់គ្រង (Control Commission Courts) របាយការណ៍សាលាឧទ្ធរណ៍ រឿងក្តីព្រហ្មទណ្ឌ (ឆ្នាំ ១៩៤៩) លេខ ១ ទំព័រ ៥៨-៦០។ អ្វីដែលសំខាន់ ថាតើទាហានអាចជា *ជនរងគ្រោះ* នៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ គឺជាសំណួរមួយដាច់ដោយឡែកពីថាតើទាហានអាចត្រូវបានចាត់ទុកជា "ប្រជាជនស៊ីវិល" ឬយ៉ាងណា។ (ឋានៈរបស់ជនរងគ្រោះជាជនស៊ីវិល ឬ ជាទាហានមិនមែនជាធាតុផ្សំនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិឡើយ)។ វាមិនមែនជាបញ្ហាដែលបានលើកឡើងដោយសហចៅក្រមស៊ើបអង្កេតអន្តរជាតិ និង មិនមែនជាប្រធានបទនៃសារណានេះឡើយ។

[41] លើសពីនេះ តាមច្បាប់សង្គ្រាម ទាំងទាហាន *ដែលគ្មានលទ្ធភាពប្រយុទ្ធ* ទាំងជនស៊ីវិលសុទ្ធតែមិនអាចជាគោលដៅស្របច្បាប់នៃការវាយប្រហារ។ *សូមមើល* អនុសញ្ញាទីក្រុងហ្សឺណែវទី ៤ ជាពិសេស មាត្រា ៣ (រួមសម្រាប់អនុសញ្ញាទីក្រុងហ្សឺណែវទាំង ៤)។

ផ្លូវការរបស់សហគមន៍ក្រូអាស៊ីនៃ Herceg-Bosna ដែលមានទាំងទាហានក្រូអាស៊ី និង មូស្លីម) ដោយសមាជិកមិនមែនមូស្លីមរបស់ HVO។ អង្គជំនុំជម្រះសាលាដំបូងបានសម្រេចថា សមាជិកមូស្លីមរបស់ HVO អាចត្រូវបានចាត់ទុកជា "បុគ្គលដែលត្រូវបានការពារ" សម្រាប់គោលបំណងនៃអនុសញ្ញាទីក្រុងហ្សឺណែវទី ៤ (ជនដែល "ធ្លាក់ចូលក្នុងកណ្ដាប់ដៃរបស់ភាគីមួយនៃជម្លោះ ដែលមិនមែនជាជនជាតិដូចពួកគេ") ដោយប្រើប្រាស់ភក្ដីភាពជាជាងសញ្ជាតិដើម្បីកំណត់ឋានៈទាហានមូស្លីមរបស់ HVO[42]។ ក្នុងការពន្លាតការការពារដល់ទាហាន ក្រោមរបបនៃការរំលោភបំពានធ្ងន់ធ្ងរ អង្គជំនុំជម្រះសាលាដំបូងបានសម្រេចថា ឋានៈរបស់ទាហានក្នុងនាមជាទាហានមិនបានផ្លាស់ប្ដូរឡើយ និង នៅតែតម្រូវឱ្យប្រជាជនគោលដៅជាជនស៊ីវិលសម្រាប់គោលបំណងនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ[43]។ រឿងក្ដីនេះស៊ីសង្វាក់គ្នានឹងលក្ខន្តិកៈ និង យុត្តិសាស្ត្រដែលរក្សាជំហរថា ភាពខុសគ្នារវាងទាហាន និង ជនស៊ីវិលនៅតែមានភាពពាក់ព័ន្ធ សូម្បីតែនៅពេលដែលវាយតម្លៃការវាយប្រហារលើទាហានរបស់រដ្ឋ ដែលផ្សេងពីប្រជាជនរបស់ខ្លួន។

១៤. នៅ អ.វ.ត.ក. អង្គជំនុំជម្រះសាលាដំបូងបានប្រើប្រាស់វិធីសាស្ត្រក្នុងរឿងក្ដី ០០១ និង រឿងក្ដី ០០២ ដូចគ្នាទៅនឹងសាលាក្ដី *មិនអចិន្ត្រៃយ៍*។ អង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់ថា៖ "សមាជិកនៃកងកម្លាំងប្រដាប់អាវុធ មិនត្រូវបានចាត់ទុកថាជា "ជនស៊ីវិល" ដោយគ្រាន់តែដោយសារពួកគេមិនបានចូលរួមនៅក្នុងការប្រយុទ្ធ នៅពេលដែលពួកគេត្រូវបានចាប់ខ្លួននោះឡើយ"[44]។ អង្គជំនុំជម្រះបានសម្រេចថា ទាហានគឺមិនមែនជាជនស៊ីវិល បើទោះបីជាគាត់មិនកាន់អាវុធ ឬ មិនបានចូលរួមនៅក្នុងការប្រយុទ្ធ ក្នុងពេលដែលមានការប្រព្រឹត្តិឧក្រិដ្ឋកម្មក៏ដោយ[45]។ ក្នុងការកំណត់អត្ថន័យនៃពាក្យ "ជនស៊ីវិល" អង្គជំនុំជម្រះសាលាដំបូងបានពិចារណាជាក់លាក់ទៅលើលទ្ធភាព

---

[42] *រឿងក្ដី រដ្ឋអាជ្ញា តទល់នឹង Prlić និង អ្នកផ្សេងទៀត* សំណុំរឿងលេខ IT-o4-74-T សាលក្រម ចុះថ្ងៃទី ២៩ ខែឧសភា ឆ្នាំ ២០១៣ ភាគ ៣ ជំពូក ៥ កថាខណ្ឌ ៦០៧-១១។

[43] *ដូចខាងលើ* កថាខណ្ឌ ៦៤៧-៤៨។

[44] *រឿងក្ដី កាំង ហ្គេកអ៊ាវ* សំណុំរឿងលេខ ០០១/១៨-០៧-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ សាលក្រម ចុះថ្ងៃទី ២៦ ខែកក្កដា ឆ្នាំ ២០១០ ឯកសារ E188 កថាខណ្ឌ ៣០៤។

[45] *រឿងក្ដី នួន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ សាលក្រមរឿងក្ដី ០០២/០១ ចុះថ្ងៃទី ៧ ខែសីហា ឆ្នាំ ២០១៤ ឯកសារ E313 កថាខណ្ឌ ១៨៦។

ដែល "ប្រជាជនទាំងអស់នៃទឹកដីមួយ ដោយរាប់បញ្ចូលទាំងប្រជាជនស៊ីវិល និង យោធា ស្ថិតនៅក្នុងការវាយប្រហារ" និង នៅតែតម្រូវឲ្យការវាយប្រហារសំដៅលើជនស៊ីវិល[46]។

១៥. ចាប់តាំងពីពេលមានតុលាការទីក្រុងនូរ៉ែប៊ែក រាល់លក្ខន្តិកៈទាំងអស់របស់សាលាក្តីអន្តរជាតិ និង អន្តរជាតូនីយកម្ម សំដៅយ៉ាងច្បាស់ទៅលើប្រជាជន *ស៊ីវិល* នៅពេលកំណត់និយមន័យឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដោយគ្មានដាក់លក្ខខណ្ឌណាមួយទៅលើពាក្យនេះឡើយ។ គ្មានទម្លាប់អនុវត្តន៍របស់រដ្ឋដែលអនុវត្តឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ទៅលើការវាយប្រហារលើទាហានរបស់រដ្ឋ ឬ ចាត់ទុកទាហានថាជាប្រជាជនស៊ីវិលឡើយ។ សូម្បីតែនៅពេលមានសន្តិភាព និង សូម្បីតែនៅពេលដែលទាហាន *គ្មានលទ្ធភាពប្រយុទ្ធ* ហើយហេតុដូច្នេះ លែងជាការគំរាមកំហែង ក៏ដោយសារៈសំខាន់ដែលស្ថិតនៅលើភាពខុសគ្នារវាងជនស៊ីវិល និង ទាហាន នៅសាលាក្តី *មិនអចិន្ត្រៃយ៍* និង នៅ អ.វ.ត.ក. បញ្ជាក់ពីលក្ខណៈមូលដ្ឋាននៃភាពខុសគ្នានេះ។ វានឹងមិនមានភាពស៊ីសង្វាក់គ្នាឡើយ នៅក្នុងការចាត់ទុកទាហានរបស់រដ្ឋមួយថាជាជនស៊ីវិល ខណៈដែលចាត់ទុកទាហាន *ដែលគ្មានលទ្ធភាពប្រយុទ្ធ* របស់រដ្ឋមួយផ្សេងទៀតថាមិនមែនជាជនស៊ីវិល ក្នុងគោលបំណងកំណត់លក្ខណៈស៊ីវិលនៃការវាយប្រហារនោះ ជាពិសេសដោយសារតែទាហាន *ដែលគ្មានលទ្ធភាពប្រយុទ្ធ* មិនអាចប្រយុទ្ធបាន ខណៈដែលទាហានរបស់រដ្ឋ អាចត្រូវបានបំពាក់អាវុធ និងបង្កគ្រោះថ្នាក់ខ្លាំងជាងនេះដល់រដ្ឋនោះ។ ច្បាប់ទំនៀមទម្លាប់អន្តរជាតិមិនគាំទ្រដល់ការបកស្រាយបែបនេះឡើយ។

**ខ. សំណួរ ២ ក៖ តើរបបមួយដែលក្នុងពេលមានសន្តិភាព បានព្យាយាមបោសសម្អាតកងកម្លាំងប្រដាប់អាវុធរបស់ខ្លួន ឧទាហរណ៍ ទាហានទាំងអស់ដែលមានជាតិពន្ធុ ឬ ជំនឿជាក់លាក់ អាចប្រព្រឹត្តអំពើឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ តាមច្បាប់ទំនៀមទម្លាប់អន្តរជាតិ ដែរឬទេ ដោយសារគុណសម្បត្តិជាយុទ្ធជនរបស់ជនរងគ្រោះ អាចមិនពាក់ព័ន្ធក្នុងបរិបទនេះនោះ?**

**ចម្លើយ៖ ទេ។ យុទ្ធនាការបែបនេះមិនអាចជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ តាមច្បាប់ទំនៀមទម្លាប់អន្តរជាតិឡើយ ប្រសិនបើត្រូវបានប្រព្រឹត្តក្នុងពេលមានសន្តិភាពនោះ។ តាមច្បាប់ទំនៀម**

[46] *រឿងក្តី កាំងហ្គេកអ៊ាវ* សំណុំរឿងលេខ ០០១/១៨-០៧-២០០៧-អ.វ.ត.ក/អ.ជ.ស.ជ សាលក្រម ចុះថ្ងៃទី ២៦ ខែកក្កដា ឆ្នាំ ២០១០ ឯកសារ E188 កថាខណ្ឌ ៣០៧។

**ទម្លាប់អន្តរជាតិ អំពើរបស់របបមួយប្រឆាំងនឹងទាហានរបស់ខ្លួនក្នុងពេលមានសន្តិភាព អាចនឹងត្រូវបានដោះស្រាយតាមច្បាប់ជាតិ។**

១៦. ច្បាប់សង្គ្រាម ទទួលស្គាល់ភាពមិនអាចរំលោភបំពានបាននៃអធិបតេយ្យភាពជាតិរបស់រដ្ឋ[47]។ គោលការណ៍នៃការមិនធ្វើអន្តរាគមន៍នៅក្នុងកិច្ចការផ្ទៃក្នុងរបស់រដ្ឋដែលមានអធិបតេយ្យភាព ត្រូវបានគោរពយ៉ាងល្អប្រសើរ នៅក្រោយសង្គ្រាមលោកលើកទី ២ ហើយបន្តមកដល់ឆ្នាំ ១៩៧៥-១៩៧៩[48]។ គ្មានទម្លាប់អនុវត្តន៍របស់រដ្ឋ ឬ *ទស្សនៈច្បាប់* ពីឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩ បង្ហាញថា រដ្ឋមានបំណងធ្វើឲ្យអធិបតេយ្យភាពចុះខ្សោយ ដោយជ្រើសរើសយកទាហានរបស់ខ្លួននៅក្នុងពេលមានសន្តិភាព ដែលធ្វើឲ្យការប្រព្រឹត្តិរបស់រដ្ឋទាំងនោះទៅលើទាហានរបស់ខ្លួន អាចត្រូវបានគ្រប់គ្រងដោយច្បាប់ព្រហ្មទណ្ឌអន្តរជាតិ ជាជាងច្បាប់ជាតិនោះឡើយ។

១៧. ជាធម្មតា ទាហានត្រូវប្រកាន់ខ្ជាប់ស្តង់ដារខុសពីជនស៊ីវិល សូម្បីតែនៅក្នុងពេលមានសន្តិភាពក៏ដោយ[49]។ ការប្រព្រឹត្តិដែលខុសគ្នានេះ គឺចាំបាច់ដើម្បីពង្រឹងវិន័យចំពោះទាហាន[50]។ កិច្ចការ

---

[47] គណៈកម្មាធិការកាកបាទក្រហមអន្តរជាតិ (ICRC) បទអត្ថាធិប្បាយអំពីពិធីសារបន្ថែមលើអនុសញ្ញាទីក្រុងហ្សឺណែវចុះថ្ងៃទី ១២ ខែសីហា ឆ្នាំ ១៩៤៩ និង ទាក់ទងនឹងការការពារជនរងគ្រោះនៃជម្លោះប្រដាប់អាវុធមិនមែនអន្តរជាតិ មាត្រា ៣ កថាខណ្ឌ ៤៥០០ ឆ្នាំ ១៩៨៧។

[48] *សូមមើល* អ.ស.ប. ធម្មនុញ្ញរបស់អង្គការសហប្រជាជាតិ ចុះថ្ងៃទី ២៤ ខែតុលា ឆ្នាំ ១៩៤៥ 1 UNTS XVI មាត្រា ២ កថាខណ្ឌ ៧។ អ.ស.ប. មហាសន្និបាត សេចក្តីប្រកាសស្តីពីភាពមិនអាចទទួលយកបាននៃការធ្វើអន្តរាគមន៍នៅក្នុងកិច្ចការផ្ទៃក្នុងរបស់រដ្ឋ និង ការការពារភាពឯករាជ្យ និង អធិបតេយ្យភាពរបស់រដ្ឋ សេចក្តីសម្រេចលេខ ២១៣១ (XX) ចុះថ្ងៃទី ២១ ខែធ្នូ ឆ្នាំ ១៩៦៥ ឯកសារ អ.ស.ប. A/RES/20/2131 (ឆ្នាំ ១៩៦៥)។ អ.ស.ប. មហាសន្និបាត សេចក្តីប្រកាសស្តីពីគោលការណ៍ច្បាប់អន្តរជាតិទាក់ទងនឹងទំនាក់ទំនងជាមិត្តភាព និង កិច្ចសហប្រតិបត្តិការក្នុងចំណោមរដ្ឋស្របតាមធម្មនុញ្ញរបស់អង្គការសហប្រជាជាតិ សេចក្តីសម្រេចលេខ ២៦២៥ (XXV) ចុះថ្ងៃទី ២៤ ខែតុលា ឆ្នាំ ១៩៧០ ឯកសារ អ.ស.ប. A/RES/25/2625 (ឆ្នាំ ១៩៧០)។ អ.ស.ប. មហាសន្និបាត សេចក្តីប្រកាសស្តីពីភាពមិនអាចទទួលយកបាននៃការធ្វើអន្តរាគមន៍ និង ការជ្រៀតជ្រែកចូលកិច្ចការផ្ទៃក្នុងរបស់រដ្ឋ សេចក្តីសម្រេចលេខ ៣៦/១០៣ ចុះថ្ងៃទី ៩ ខែធ្នូ ឆ្នាំ ១៩៨១ ឯកសារ អ.ស.ប. A/RES/36/103 (ឆ្នាំ ១៩៨១)។

[49] *សូមមើល* ក្រមតុលាការយោធាកម្ពុជាឆ្នាំ ១៩៥៤ ដែលបង្កើតប្រព័ន្ធតុលាការយោធាដាច់ដោយឡែកមួយ ដែលអនុវត្តចំពោះទាហាន ប៉ុន្តែមិនចំពោះជនស៊ីវិល និង អនុវត្តក្នុងពេលមានសន្តិភាព ព្រមទាំងក្នុងពេលមានសង្គ្រាមផងដែរ។ *សូមមើលផងដែរ* សេចក្តីព្រាងច្បាប់ស្តីពីការបង្កើតក្រមតុលាការយោធា (Projet de loi portant institution d'un code de justice militaire) ព្រឹទ្ធសភាបារាំង ចុះថ្ងៃទី ៨ ខែកក្កដា ឆ្នាំ ១៩៦៥។ ក្រមតុលាកាយោធារួមនៃសហរដ្ឋអាមេរិក (United States Uniform Code of Military Justice) (10 U.S.C. §§ 801–946) ដែលចូលជាធរមាននៅឆ្នាំ ១៩៥១។ *រឿងក្តី Parker តទល់នឹង Levy* ៤១៧ ស.រ.អ. ៨៣៣ ៧៤៣ (ឆ្នាំ ១៩៧៤)៖ "តាមភាពចាំបាច់ យោធាគឺជាសង្គមជំនាញមួយដែលដាច់ចេញពីសង្គមស៊ីវិល...។ ជា

ចម្បងរបស់ទាហានគឺត្រូវប្រយុទ្ធក្នុងសង្គ្រាម[51]។ ហេតុដូចនេះ ពួកគេជាជនដែលមានគ្រោះថ្នាក់ជាងជនស៊ីវិល។ រដ្ឋមានផលប្រយោជន៍ជានិច្ច នៅក្នុងការរក្សាលទ្ធភាពដោះស្រាយបញ្ហាជាមួយទាហានរបស់ខ្លួនជាលក្ខណៈផ្ទៃក្នុង ពោលគឺទាំងការដោះស្រាយការបះបោរផ្ទៃក្នុងដែលអាចកើតមានពីសំណាក់ទាហាន ទាំងលទ្ធភាពក្នុងការអនុវត្តយុទ្ធវិធីយោធាស្របច្បាប់។ ច្បាប់ជាតិដោះស្រាយស្ថានភាពបែបនេះ[52]។

១៨. ប្រសិនបើការប្រព្រឹត្តិរបស់រដ្ឋទៅលើទាហានរបស់ខ្លួនផ្ទាល់ក្នុងពេលមានសន្តិភាព ជាកម្មវត្ថុនៃច្បាប់ព្រហ្មទណ្ឌអន្តរជាតិនោះ រដ្ឋអាចនឹងត្រូវបានចោទប្រកាន់ពីឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិចំពោះការវាយប្រហារលើទាហានរបស់ខ្លួន ប្រសិនបើទាហានទាំងនោះបានបែរខ្នងប្រឆាំងនឹងរដ្ឋនោះ។ ឧទាហរណ៍ដូចជា ការបះបោរ ឬ ការប៉ុនប៉ងធ្វើរដ្ឋប្រហារជាដើម។ រដ្ឋមិនចង់បានលទ្ធផលបែបនេះទេ ដូចដែលត្រូវបានបង្ហាញដោយពិធីសារបន្ថែម II ដូច្នេះដែរ។ ពិធីសារបន្ថែម II អនុវត្ត ក្នុងអំឡុងពេលជម្លោះប្រដាប់អាវុធមិនមែនអន្តរជាតិរវាងកងកម្លាំងប្រដាប់អាវុធរបស់ភាគីរដ្ឋ និង កងកម្លាំងប្រដាប់អាវុធរបស់ក្រុមប្រឆាំង ឬ ក្រុមប្រដាប់អាវុធដែលមានអង្គការចាត់តាំងផ្សេងទៀត ដែលស្ថិតក្រោមការបញ្ជាប្រកបដោយការទទួលខុសត្រូវ ប្រតិបត្តិការគ្រប់គ្រងដែនដីដែលអាចឲ្យពួកគេអនុវត្តប្រតិបត្តិការយោធាទៅតាមផែនការ និង ប្រកបដោយនិរន្តភាព និង អនុវត្តពិធីសារបន្ថែម II[53]។ មាត្រា ៣(១) នៃពិធីសារបន្ថែម II ចែងថា ពិធីសារបន្ថែម II មិនត្រូវបានយកមកប្រើដើម្បីធ្វើឲ្យមាន "ផលប៉ះពាល់ដល់អធិបតេយ្យភាពនៃរដ្ឋ ឬ ការទទួលខុសត្រូវរបស់រដ្ឋាភិបាល តាមរយៈមធ្យោបាយស្របច្បាប់ទាំងអស់ ដើម្បីរក្សា ឬ បង្កើតឡើងវិញនូវច្បាប់ និង សណ្តាប់ធ្នាប់នៅក្នុងរដ្ឋនោះ ឬ ការពារឯកភាពជាតិ និង បូរណភាពដែនដីរបស់រដ្ឋ" នោះទេ។

១៩. បទអត្ថាធិប្បាយនៅឆ្នាំ ១៩៨៧ របស់ ICRC អំពីពិធីសារបន្ថែម II ពន្យល់ថា មាត្រា ៣(១) មិនធ្វើឲ្យប៉ះពាល់ដល់ "សិទ្ធិរបស់រដ្ឋក្នុងការចាត់វិធានការសមស្រប ដើម្បីរក្សា ឬ ស្តារឡើងវិញនូវ

---

ថ្មីម្តងទៀតទៅតាមភាពចាំបាច់ យោធាបានបង្កើតច្បាប់ និង ប្រពៃណីផ្ទាល់របស់ខ្លួនក្នុងអំឡុងពេលប្រវត្តិសាស្ត្រដ៏វែងរបស់ខ្លួន"។

[50] Louis B. Nichols *យុត្តិធម៌របស់តុលាការយោធា* 12 Wm. & Mary L. Rev. 482, 483-84 (ឆ្នាំ ១៩៧១)។

[51] *រឿងក្តី Parker តទល់នឹង Levy* ៤១៧ ស.រ.អ. ៧៣៣ ៧៤៣ (ឆ្នាំ ១៩៧៤)។

[52] ឧទាហរណ៍ ក្នុងប្រទេសកម្ពុជា ចារីនៃឧក្រិដ្ឋកម្មប្រឆាំងនឹងទាហាន អាចនឹងជាកម្មវត្ថុនៃក្រមតុលាការយោធាកម្ពុជាឆ្នាំ ១៩៥៤ ឬ ក្រមព្រហ្មទណ្ឌឆ្នាំ ១៩៥៦។

[53] មាត្រា ១(១) នៃពិធីសារបន្ថែម II។

ច្បាប់ និង សណ្តាប់ធ្នាប់ ការពារឯកភាពជាតិ និង បូរណភាពដែនដីរបស់រដ្ឋទាំងនោះ”[54] ឡើយ។ រដ្ឋទទួលស្គាល់ថា អាចមានស្ថានភាពដែលរដ្ឋទាំងនោះ អាចចាំបាច់ត្រូវវាយប្រហារលើកងកម្លាំងប្រដាប់អាវុធដែលបះបោរ។ រដ្ឋទាំងនោះបានបង្កើតបទប្បញ្ញត្តិជាក់លាក់ ដើម្បីគ្រប់គ្រងអំពើបែបនេះ ជាជាងហាមឃាត់រដ្ឋមិនឲ្យវាយប្រហារលើទាហានរបស់ខ្លួននៅក្នុងស្ថានភាពបែបនេះ។ ផលប្រយោជន៍របស់រដ្ឋនៅក្នុងការរក្សាអធិបតេយ្យភាពរបស់ខ្លួន និង គ្រប់គ្រងយោធារបស់រដ្ឋទាំងនោះជាលក្ខណៈផ្ទៃក្នុង បង្ហាញថា រដ្ឋទាំងនោះ អាចនឹងមិនមានបំណងដាក់បញ្ចូលការវាយប្រហារទៅលើទាហានរបស់រដ្ឋ នៅក្នុងពេលសន្តិភាព ទៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ។

២០. ប្រសិនបើឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ អាចត្រូវបានប្រព្រឹត្តដោយរដ្ឋប្រឆាំងនឹងទាហានរបស់ខ្លួនមែននោះ នៅក្នុងស្ថានភាពមួយចំនួន រដ្ឋអាចត្រូវបានចោទប្រកាន់ពីបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដោយសារការប្រើប្រាស់ទាហានរបស់ខ្លួនក្នុងយុទ្ធវិធីយោធាស្របច្បាប់។ រដ្ឋដែលប្រើប្រាស់ទាហានរបស់ខ្លួនឲ្យធ្វើជាអ្នកបើកបរយន្តហោះអត្តឃាត (kamikaze pilots)[55] ក្នុងគោលបំណងឲ្យពួកគេស្លាប់ ដើម្បីសម្រេចបានគោលបំណងយោធាជាក់លាក់នោះ អាចត្រូវបានចាត់ទុកថាបាន

---

[54] គណៈកម្មាធិការកាកបាទក្រហមអន្តរជាតិ (ICRC) បទអត្ថាធិប្បាយអំពីពិធីសារបន្ថែមលើអនុសញ្ញាទីក្រុងហ្សឺណែវ ចុះថ្ងៃទី ១២ ខែសីហា ឆ្នាំ ១៩៤៩ និង ទាក់ទងនឹងការការពារជនរងគ្រោះពីជម្លោះប្រដាប់អាវុធមិនមែនអន្តរជាតិ មាត្រា ៣ កថាខណ្ឌ ៤៥០០ ឆ្នាំ ១៩៨៧ សូមកត់សម្គាល់ផងដែរថា មាត្រា ៣(១) បញ្ជាក់ជាថ្មីអំពីគោលការណ៍នៃភាពមិនអាចរំលោភបាននៃអធិបតេយ្យភាពជាតិរបស់រដ្ឋ។

[55] អ្នកបើកបរយន្តហោះអត្តឃាតត្រូវបានប្រើប្រាស់ដោយជប៉ុនក្នុងសង្គ្រាមលោកលើកទី ២ ដើម្បីហោះទៅបុកកប៉ាល់ចម្បាំងរបស់ខ្មាំង។ ខណៈដែលយុទ្ធវិធីយោធានេះ មានការខាតបង់ច្រើន យុទ្ធវិធីនេះបានបង្កឲ្យកប៉ាល់ចម្បាំងរបស់ក្រុមសម្ព័ន្ធមិត្តចំនួន ២៦៣ លិច ឬ ខូចខាត ហើយត្រូវបានរាយការណ៍ថាបានបង្កផលប៉ះពាល់ដ៏ធំធេងដល់ផែនការរបស់ក្រុមសម្ព័ន្ធមិត្តទាក់ទងនឹងការឈ្លានពានជប៉ុន។ សព្វវចនាធិប្បាយអន្តរជាតិនៃប្រវត្តិយោធា (International Encyclopedia of Military History) 706 (បោះពុម្ពផ្សាយដោយ James C. Bradford ឆ្នាំ ២០១៥)។ Yoram Dinstein ពន្យល់ថា៖ “ការវាយប្រហារអត្តឃាតមួយចំនួន (ដែលបានអនុវត្តដោយអ្នកបើកបរយន្តហោះអត្តឃាតជប៉ុនក្នុងសង្គ្រាមលោកលើកទី ២ ដែលបានបើកបរយន្តហោះយោធាមានស្លាកសញ្ញាសម្គាល់ត្រឹមត្រូវ) គឺជាសញ្ញាណដ៏ក្លាហាននៃការប្រយុទ្ធស្របច្បាប់”។ YORAM DINSTEIN អំពើប្រទូស្តសាវ៉ាយក្រោមច្បាប់ស្តីពីជម្លោះប្រដាប់អាវុធអន្តរជាតិ កំណត់សម្គាល់លេខ ២៣៥ (បោះពុម្ពលើកទី ៣ សារព័ត៌មានសកលវិទ្យាល័យ Cambridge ឆ្នាំ ២០១៦)។

ប្រព្រឹត្តឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ[56]។ រដ្ឋនឹងមិនមានបំណងបង្កើតច្បាប់មួយ ដែលរារាំងដល់ការអនុវត្តយុទ្ធសាស្ត្រយោធាទៅលើគោលដៅស្របច្បាប់នោះឡើយ។

២១. សម្រាប់គោលបំណងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ច្បាប់ទំនៀមទម្លាប់អន្តរជាតិតម្រូវឱ្យប្រជាជនជាគោលដៅនៃការវាយប្រហារជាជនស៊ីវិល[57]។ សូម្បីតែនៅពេលមានសន្តិភាព ច្បាប់ទំនៀមទម្លាប់អន្តរជាតិមិនទទួលស្គាល់ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ក្នុងករណីដែលប្រជាជនជាគោលដៅមានចំនួនទាហានលើសលុបនោះឡើយ។ ក្តីបារម្ភណាមួយដែលថា ការខ្វះចន្លោះក្នុងការការពារផ្នែកច្បាប់ចំពោះទាហានអាចកើតមានឡើង ប្រសិនបើរដ្ឋមិនអាចត្រូវបានកាត់ទោសពីបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិប្រព្រឹត្តទៅលើទាហានរបស់ខ្លួននោះ គឺមិនមានមូលដ្ឋានឡើយ។ នៅក្នុងកាលៈទេសៈមួយចំនួន រដ្ឋអាចត្រូវបានកាត់ទោសពីបទប្រព្រឹត្តអំពើប្រល័យពូជសាសន៍ពាក់ព័ន្ធនឹងទាហានរបស់ខ្លួន[58] បន្ថែមលើការប្រឈមនឹងការកាត់ទោសថ្នាក់ជាតិ។ តាមច្បាប់ទំនៀមទម្លាប់អន្តរជាតិជាធរមាន ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ អនុវត្តបានតែចំពោះប្រជាជន *ស៊ីវិល* ប៉ុណ្ណោះ។ មាត្រា ៥ នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក. ទទួលស្គាល់ និង អនុវត្តនិយមន័យនេះ[59]។ លក្ខខណ្ឌតម្រូវ *ទូទៅ* (Chapeau) នៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ មិនអាចត្រូវបានពន្លាតនៅ អ.វ.ត.ក. ដើម្បីគ្របការវាយប្រហារដែលគ្រាន់តែ "ជាចម្បង"[60] សំដៅលើប្រជាជន

---

[56] ការវាយប្រហារអាចត្រូវបានឱ្យនិយមន័យថាជាដំណើរឆ្ពោះទៅរកអំពើខុសច្បាប់ ដូចជាអំពើទាំងឡាយណាដែលមានចែងក្នុងមាត្រា ៥ នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក. (ឧ. ឃាតកម្ម)។ *រឿងក្តី នួន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ សាលក្រមរឿងក្តី ០០២/០១ ចុះថ្ងៃទី ៧ ខែសីហា ឆ្នាំ ២០១៤ ឯកសារ E313 កថាខណ្ឌ ១៧៨។

[57] *សូមមើល ខាងលើ* កថាខណ្ឌ ៣-១៥។

[58] មិនដូចទៅនឹងឧក្រិដ្ឋកម្មសង្គ្រាម ឬ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិពីឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩ អំពើប្រល័យពូជសាសន៍ មិនតម្រូវឱ្យអំពើត្រូវបានប្រព្រឹត្តប្រឆាំងនឹងប្រជាជនស៊ីវិលនោះទេ ហើយអាចកើតឡើងក្នុងពេលមានសន្តិភាព។ *សូមមើល* មាត្រា II នៃអនុសញ្ញាស្តីពីការទប់ស្កាត់ និង ផ្តន្ទាទោសចំពោះអំពើឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ដែលត្រូវបានអនុម័តដោយមហាសន្និបាត អ.ស.ប. ចុះថ្ងៃទី ៩ ខែធ្នូ ឆ្នាំ ១៩៤៨។

[59] មាត្រា ៥ នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក. (គូសបញ្ជាក់បន្ថែម)៖ "ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដែលគ្មានអាជ្ញាយុកាលគឺអំពើណាមួយដូចខាងក្រោម ដែលវាយប្រហារជាទូទៅ ឬ ដោយមានការរៀបចំ**ប្រឆាំងទៅលើប្រជាជនស៊ីវិល**ដោយមូលហេតុជាតិ នយោបាយ ជាតិពន្ធុ ពូជសាសន៍ ឬ សាសនា..."។

[60] *សូមមើល* សេចក្តីអំពាវនាវសុំឱ្យដាក់សារណា កថាខណ្ឌ ១។ សហចៅក្រមស៊ើបអង្កេតអន្តរជាតិទំនងជាដកស្រង់មាត្រា ៥ នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក. មិនបានត្រឹមត្រូវ ដែលគាត់ថ្លែងថា ការវាយប្រហារត្រូវតែ "សំដៅជាចម្បង" ទៅលើប្រជាជនស៊ីវិល។ គាត់ពឹងផ្អែកលើយុត្តិសាស្ត្ររបស់សាលាក្តី ICTY ដែលបង្ហាញត្រឹមតែថា ឃ្លា "សំដៅទៅលើ" នៅក្នុងនិយម

ស៊ីវិល ឬ សំដៅលើប្រជាជនដែលមិនមែនជាជនស៊ីវិល រួមទាំងទាហានផងដែរនោះឡើយ។ ការវាយប្រហារត្រូវតែធ្វើឡើងសំដៅទាំងស្រុងទៅលើប្រជាជន *ស៊ីវិល* ។

**គ. សំណួរ ២ ខ៖ តើរបបមួយដែលបានព្យាយាមបោសសម្អាតកងកម្លាំងប្រដាប់អាវុធរបស់ខ្លួន ឧទាហរណ៍ ទាហានទាំងអស់ដែលមានជាតិពន្ធុ ឬ ជំនឿជាក់លាក់ នៅក្នុងពេល ឬ បើមិនដូច្នោះទេ ជាប់ទាក់ទងនឹងជម្លោះប្រដាប់អាវុធ អាចប្រព្រឹត្តឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដែរ ឬទេ តាមច្បាប់ទំនៀមទម្លាប់អន្តរជាតិ?**

**ចម្លើយ៖ ទេ។ ក្នុងអំឡុងពេលមានជម្លោះប្រដាប់អាវុធ ប្រសិនបើបុគ្គលមិនមែនជាជនស៊ីវិល (ដូចជា ទាហានសកម្ម ទាហាន *ដែលគ្មានលទ្ធភាពប្រយុទ្ធ* ឬ ទាហានដែលត្រូវបានឃុំខ្លួន) គឺជាគោលដៅនៃការវាយប្រហារដោយរដ្ឋរបស់ខ្លួននោះ ការវាយប្រហារបែបនេះអាចជាការរំលោភទៅលើច្បាប់មនុស្សធម៌អន្តរជាតិ ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ឬ ច្បាប់ជាតិ អាស្រ័យទៅតាមកាលៈទេសៈ។ អំពើនេះមិនអាចជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនោះឡើយ។**

២២. ក្នុងអំឡុងពេលជម្លោះប្រដាប់អាវុធ មនុស្សគ្រប់រូបគឺជាគោលដៅយោធាស្របច្បាប់ ឬ ក៏ជាបុគ្គលដែលត្រូវបានការពារប្រឆាំងនឹងការវាយប្រហារដោយផ្ទាល់។ ប្រភេទទាំងពីរនេះមិនអាចរួមបញ្ចូលគ្នាបាននោះទេ[61]។ អនុសញ្ញាទីក្រុងហ្សឺណែវ បានបង្ហាញពីភាពខុសគ្នារវាងការការពារដែលផ្តល់ទៅឲ្យទាហាន និង ការការពារដែលផ្តល់ទៅឲ្យជនស៊ីវិលក្នុងអំឡុងពេលមានជម្លោះប្រដាប់អាវុធ[62]។ ដូចដែលបានបង្ហាញដោយរឿងក្តី *Prlić និង អ្នកផ្សេងទៀត* នៅសាលាក្តី

---

ន័យនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិរបស់សាលាក្តី ICTY តម្រូវថា ប្រជាជនស៊ីវិលត្រូវតែជា "គោលដៅចម្បងនៃការវាយប្រហារ ជាជាងជាគោលដៅបន្ទាប់បន្សំ"។ *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង* *Kunarac* សំណុំរឿងលេខ IT-96-23 & IT-96-23/1-A សាលក្រម ចុះថ្ងៃទី ១២ ខែមិថុនា ឆ្នាំ ២០០២ កថាខណ្ឌ ៩២។

[61] Nils Melzer *គោលការណ៍នៃភាពខុសគ្នារវាងជនស៊ីវិល និង យុទ្ធជន* សៀវភៅច្បាប់អន្តរជាតិក្នុងជម្លោះប្រដាប់អាវុធរបស់សាកលវិទ្យាល័យ Oxford ទំព័រ ២៩១-៩៧ (បោះពុម្ពផ្សាយដោយ Andrew Clapham & Paola Caeta សារព័ត៌មានសកលវិទ្យាល័យ Oxford ឆ្នាំ ២០១៤)។

[62] មាត្រា ៣ រួម តម្រូវថា ជនដែលមិនបានចូលរួមយ៉ាងសកម្មក្នុងការប្រទូស្តសារ៉ាយត្រូវទទួលរងការប្រព្រឹត្តប្រកបដោយមនុស្សធម៌។ ទាហានដែលដាក់អាវុធចុះ រងរបួស ត្រូវបានឃុំខ្លួន ឬ ធ្លាក់ខ្លួនឈឺក្នុងអំឡុងពេលជម្លោះ នៅតែត្រូវបានការពារដោយមាត្រា ៣ មាត្រា ១២ និង មាត្រា ១៣(១) នៃអនុសញ្ញាទីក្រុងហ្សឺណែវទីមួយ។ ការការពារនេះអាចកើតមានទាក់ទងនឹងរដ្ឋរបស់ទាហាន ព្រមទាំងរដ្ឋជាគូបដិបក្ខ។ *សូមមើល* បទអត្ថាធិប្បាយអំពីអនុសញ្ញាទីក្រុងហ្សឺណែវទីមួយ (ឆ្នាំ ២០១៦) ផ្នែក

ICTY[63] អាស្រ័យទៅតាមឋានៈរបស់ពួកគេ បុគ្គលដែលមិនមែនជាជនស៊ីវិល អាចត្រូវបានការពារដោយច្បាប់សង្គ្រាម ប៉ុន្តែមិនមានសិទ្ធិទទួលបានការការពារក្នុងកម្រិតដូចគ្នានឹងជនស៊ីវិលឡើយ។

២៣. ការវាយប្រហាររបស់រដ្ឋទៅលើទាហានរបស់ខ្លួន មិនមែនជាល្បែងមានលទ្ធផលសូន្យ (Zero-sum game) នោះទេ។ ពោលគឺ ការវាយប្រហារនោះគឺជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ឬ ក៏មិនមែនជាឧក្រិដ្ឋកម្ម។ ប្រសិនបើរបបមួយប៉ុនប៉ងបោសសម្អាតកងកម្លាំងប្រដាប់អាវុធរបស់ខ្លួនក្នុងពេលមានជម្លោះប្រដាប់អាវុធ ការបោសសម្អាតនេះអាចជាការរំលោភច្បាប់មនុស្សធម៌អន្តរជាតិ[64] ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ឬ ការរំលោភច្បាប់ជាតិ អាស្រ័យទៅតាមកាលៈទេសៈរបស់អំពើនោះ។ អំពើនេះមិនមែនជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិឡើយ។

## III សេចក្តីសន្និដ្ឋាន

២៤. តាមច្បាប់ទំនៀមទម្លាប់អន្តរជាតិជាធរមាន ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ អនុវត្តតែចំពោះប្រជាជន *ស៊ីវិល* ប៉ុណ្ណោះ។ ទាហាន មិនថាជាទាហានរបស់រដ្ឋ ឬ ជាទាហានរបស់ខ្មាំង *ជានិច្ចកាល* គឺខុសគ្នាពីជនស៊ីវិល។ មិនថាស្ថិតក្នុងពេលមានសន្តិភាព ឬ ក្នុងពេលមានសង្គ្រាមនោះទេ អំពើរបស់រដ្ឋប្រឆាំងនឹងទាហានរបស់ខ្លួន មិនមែនជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិឡើយ។ គ្មានទម្រង់គោលនយោបាយសមហេតុផលសាមញ្ញណាមួយ ដែលត្រូវបានមើលរំលងដោយរដ្ឋនោះទេ គិតចាប់តាំងពីពេលមានតុលាការទីក្រុងនូរ៉ែប៊ែក។

---

យ កថាខណ្ឌ ១។ អនុសញ្ញាទីក្រុងហ្សឺណែវទីបី ការពារឈ្លើយសឹក (យុទ្ធជនដែលបានធ្លាក់ចូលក្នុងកណ្តាប់ដៃរបស់ខ្មាំង)។ មាត្រា ៤ នៃអនុសញ្ញា (III) ដែលទាក់ទងនឹងការប្រព្រឹត្តទៅលើឈ្លើយសឹក ទីក្រុងហ្សឺណែវ ចុះថ្ងៃទី ១២ ខែសីហា ឆ្នាំ ១៩៤៩ ។ អនុសញ្ញាទីក្រុងហ្សឺណែវទីបួន ការពារជន (មិនមែនជាទាហាន) ដែលមិនទទួលបានការការពារពីអនុសញ្ញាទីក្រុងហ្សឺណែវផ្សេងទៀត និង ដែលមិនស្ថិតក្នុងកណ្តាប់ដៃរបស់ភាគីមួយ ឬ អ្នកកំពុងកាន់កាប់អំណាចដែលមិនមែនជាជាតិសាសន៍ដូចពួកគេ។ មាត្រា ៤ នៃអនុសញ្ញា (IV) ដែលទាក់ទងនឹងការការពារជនស៊ីវិលក្នុងពេលមានសង្គ្រាម ទីក្រុងហ្សឺណែវ ចុះថ្ងៃទី ១២ ខែសីហា ឆ្នាំ ១៩៤៩។

[63] បើទោះជាមានការពង្រីកការការពាររហូតទៅដល់ទាហានមូស្លីមរបស់ HVO តាមរបបនៃការរំលោភបំពានធ្ងន់ធ្ងរក៏ដោយ ក៏អង្គជំនុំជម្រះសាលាដំបូង តម្រូវឱ្យប្រជាជនជាគោលដៅត្រូវតែជាជនស៊ីវិលសម្រាប់គោលបំណងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ។ *សូមមើល ខាងលើ* កថាខណ្ឌ ១៣។

[64] Henckaerts ច្បាប់ទំនៀមទម្លាប់មនុស្សធម៌អន្តរជាតិ ភាគ ១ វិធាន ១៥៦។

២៥. ការសម្រេចដែលថាការវាយប្រហារអាចត្រូវបានធ្វើឡើងសំដៅលើទាហាន ធ្វើឲ្យនិយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិក្នុងមាត្រា ៥ អានចេញជាន័យពីរ[65]។ មិនត្រូវព្រងើយកន្តើយនឹងភាសាច្បាប់ គ្រាន់តែដោយសារវាអាចនាំឲ្យមានភាពមិនត្រឹមត្រូវនោះទេ[66]។ ការសង្ស័យណាមួយទាក់ទងនឹងអត្ថន័យនៃពាក្យ "ជនស៊ីវិល" ត្រូវតែបកស្រាយដោយមានភាពអំណោយផលបំផុតដល់លោក មាស មុត ស្របតាមមាត្រា ៣៨ នៃរដ្ឋធម្មនុញ្ញកម្ពុជា និង គោលការណ៍វិមតិសង្ស័យបានជាប្រយោជន៍ដល់ជនជាប់ចោទ (in dubio pro reo)[67]។

២៦. អ.វ.ត.ក. ត្រូវអនុវត្តច្បាប់ជាធរមានពីឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩។ វាមិនមែនជាតួនាទីរបស់តុលាការឡើយ ក្នុងការ "បំពេញការខ្វះចន្លោះ [ដែលត្រូវបានមើលឃើញ] តាមរយៈយុត្តិសាស្ត្ររបស់ខ្លួន" នោះ[68]។ បញ្ហា *មិនមែន* ស្ថិតនៅត្រង់ថាអ្វីដែលគួរជាច្បាប់នោះទេ ប៉ុន្តែស្ថិតនៅត្រង់ថា

---

[65] មិនត្រឹមតែពាក្យ "ជនស៊ីវិល" ប៉ុណ្ណោះទេដែលត្រូវបានព្រងើយកន្តើយ ពាក្យ "ប្រជាជន" ក៏មិនត្រូវបានអើពើផងដែរ។ ការបកស្រាយលក្ខខណ្ឌតម្រូវដែលថា ការវាយប្រហារត្រូវសំដៅលើ "ប្រជាជន" គ្រាន់តែជាមធ្យោបាយមួយទៀតដែលតម្រូវឲ្យការវាយប្រហារមានលក្ខណៈ "ជាទូទៅ ឬ ជាប្រព័ន្ធ" (ពោលគឺថា ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ មិនមែនជាអំពើដែលកើតឡើងតែឯង ឬ ជាអំពើចៃដន្យ ប៉ុន្តែទាមទារឲ្យមានបរិបទទូលំទូលាយជាងនេះ) នោះ ធ្វើឲ្យពាក្យ "ប្រជាជន" មិនមានភាពចាំបាច់។ វាមានអត្ថន័យតែនៅពេលណាដែលត្រូវបានបញ្ជាក់អត្ថន័យដោយពាក្យ "ស៊ីវិល" ប៉ុណ្ណោះ។

[66] គោលការណ៍នៃ verba quae aliquid operari possunt non debent esse superflua ចែងថា ពាក្យដែលអាចមានឥទ្ធិពលមួយចំនួន មិនគួរត្រូវបានចាត់ទុកថាមិនចាំបាច់ឡើយ។ វាគឺជាគោលការណ៍មូលដ្ឋាននៃការបកស្រាយច្បាប់ដែលតុលាការគួរផ្តល់ប្រសិទ្ធភាពដល់គ្រប់ពាក្យនៃលក្ខន្តិកៈ។ សេវាកម្មស្រាវជ្រាវសភា *ការបកស្រាយច្បាប់៖ គោលការណ៍ទូទៅ និង និន្នាការបច្ចុប្បន្ន* ទំព័រ ១៣-១៤។

[67] *សូមមើល រឿងក្តី នួន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក-អ.ជ.ស.ដ/អ.ជ.ត.ក(០៤) សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗរបស់ ខៀវ សំផន ស្តីពីសំណើសុំដោះលែងជាបន្ទាន់ ចុះថ្ងៃទី ៦ ខែមិថុនា ឆ្នាំ ២០១១ ឯកសារ E50/3/1/4 កថាខណ្ឌ ៣១។ ការណ៍នេះគឺជាការពិតជាក់លាក់ ដោយសារការបកស្រាយទូលំទូលាយនៃឃ្លា "ការវាយប្រហារទៅលើប្រជាជនស៊ីវិល" ដែលរួមបញ្ចូលទាំងការវាយប្រហារទៅលើទាហានដែរនោះ មិនអាចប្រមើលមើលឃើញជាមុន ឬ មិនអាចដឹងបាន នៅឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩។ *សូមមើល រឿងក្តី នួន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក-អ.ជ.ស.ដ/ក.ស.ច.ស (អ.ប.ជ ៧៥) សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី ១១ ខែមេសា ឆ្នាំ ២០១១ ឯកសារ D427/1/30 កថាខណ្ឌ ២១០ (ដែលពន្យល់ថា ភាពអាចប្រមើលមើលឃើញជាមុន និង អាចដឹងបាន គឺជាធាតុផ្សំនៃគោលការណ៍នីត្យានុកូលភាព ដែលត្រូវតែបំពេញមុនពេលដែលឧក្រិដ្ឋកម្មអាចត្រូវបានអនុវត្តនៅ អ.វ.ត.ក.)។

[68] នៅសាលាក្តី ICTY អង្គជំនុំជម្រះទទួលស្គាល់ថា សូម្បីតែនៅក្នុងករណីដែលខ្លួនមើលឃើញ "ភាពឆកល្វែងខាងការការពារ" នៅក្នុងច្បាប់ក្តី ក៏ភាពឆកល្វែងទាំងនោះនៅមានកម្រិតដែរ តាមរយៈការប្រើពាក្យក្នុងលក្ខន្តិកៈរបស់សាលាក្តី ICTY ហើយអាចមិនបំពេញភាពឆកល្វែងទាំងនេះបានតាមរយៈយុត្តិសាស្ត្រ។ *សូមមើល រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Mrkšić និង អ្នកផ្សេងទៀត*

តើអ្វីជាច្បាប់ទំនៀមទម្លាប់អន្តរជាតិពីឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩ ហើយថាតើច្បាប់នោះអាចត្រូវបានអនុវត្តយ៉ាងដូចម្ដេចដើម្បីឱ្យស្របតាមច្បាប់ស្ដីពីការបង្កើត អ.វ.ត.ក.។

សូមលោកចៅក្រមមេត្តាទទួលយកសារណានេះដោយក្ដីគោរព។

ធ្វើនៅរាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ថ្ងៃទី **១៩** ខែ **ឧសភា** ឆ្នាំ **២០១៦**

សហមេធាវីការពារក្ដីលោក មាស មុត

| | |
|---|---|
| ______________ | ______________ |
| **អាង ឧត្ដម** | Michael G. KARNAVAS |

---

សំណុំរឿងលេខ IT-95-13/1-T សាលក្រម ចុះថ្ងៃទី ២៧ ខែកញ្ញា ឆ្នាំ ២០០៧ កថាខណ្ឌ ៤៦០។ អង្គជំនុំជម្រះសាលាដំបូងក្នុងរឿងក្ដី *Mrkšić* បានសន្និដ្ឋានដោយមិនត្រឹមត្រូវថា ជនរងគ្រោះនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ត្រូវតែជាជនស៊ីវិលស្របតាមលក្ខខណ្ឌតម្រូវរបស់សាលាក្ដី ICTY។ អង្គជំនុំជម្រះសាលាឧទ្ធរណ៍ បានច្រានចោលការសម្រេចនេះ ដោយរកឃើញថា លក្ខន្តិកៈរបស់សាលាក្ដី ICTY មិនមានការកំណត់បែបនេះឡើយ។ *រឿងក្ដី រដ្ឋអាជ្ញា តទល់នឹង Mrkšić និង អ្នកផ្សេងទៀត* សំណុំរឿងលេខ IT-95-13/1-A សាលក្រម ចុះថ្ងៃទី ៥ ខែឧសភា ឆ្នាំ ២០០៩ កថាខណ្ឌ ២៩ ដែលសំដៅលើ *រឿងក្ដី រដ្ឋអាជ្ញា តទល់នឹង Martić* សំណុំរឿងលេខ IT-95-11-A សាលក្រម ចុះថ្ងៃទី ៨ ខែតុលា ឆ្នាំ ២០០៨ កថាខណ្ឌ ៣០៧។